សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Économiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការប្រៀបធៀបបទល្មើសឆបោក និង រំលោភលើទំនុកចិត្ត

ស្រាវជ្រាវពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨


ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ ១.លោក លន់ ផល្លី

២.លោក សំ សុផល

សាស្ត្រាចារ្យណែនាំ៖

លោក ជួន ម៉ុនធី


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ១៨

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

ជាដំបូងយើងខ្ញុំឈ្មោះ **លន់ ផល្លី** និង **សំ សុផល** ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចជំនាន់ទី១៨ ឆ្នាំសិក្សា២០១៥-២០១៨។ សូមថ្លែងអំណរអរគុណ និងសម្តែងនូវកតញ្ញូតាធម៌ យ៉ាងជ្រាលជ្រៅបំផុតចំពោះ **លោកឪពុក** និង**អ្នកម្តាយ** ទាំងពីរសងខាងដែលបានផ្តល់កំណើតដល់រូបកូន ព្រមទាំងខិតខំពុះពារគ្រប់ឧបស័គ្គដើម្បីចិញ្ចឹមបីបាច់ថែរក្សា មិនថាក្តៅរងា ឬយប់ថ្ងៃឡើយតាំងពីមិនទាន់ដឹងក្តីរហូតមកដល់ពេលនេះ។ ជាពិសេសជាងនេះទៅទៀតនោះ លោកទាំងពីរបាន ទូន្មានប្រៀនប្រដៅ អប់រំ និងបានជួយទំនុបប ម្រុងការសិក្សារៀនសូត្ររបស់យើងខ្ញុំតាំងពីបឋមសិក្សា រហូតដល់សាកលវិទ្យាល័យ។ លើសពីនេះទៅទៀតនោះគឺលោកអ្នកមានគុណទាំងពីរបានចំណាយនូវកម្លាំងកាយចិត្ត ក្នុងការអប់រំទូន្មានរូបកូនឱ្យក្លាយជាកូនល្អ និស្សិតល្អ និងក្លាយជាពលរដ្ឋល្អម្នាក់នៅក្នុងសង្គម។ កូនសូមលើកដៃទាំងទ្វេប្រណមលើកឡើងសូមបួងសួងដល់អស់ទេវតា និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមព្រះមេត្តាតាមជួយថែរក្សាលោកឪពុក និងអ្នកម្តាយដែលមានតម្លៃស្មើជីវិតកូន ឱ្យបានជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងចៀសផុតពីរោគាព្យាធិទាំងឡាយទាំងពួង។

ជាបន្តទៀតនេះដែល យើងខ្ញុំសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

- **ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- លោកគ្រូសាស្ត្រាចារ្យ **ជួន ម៉ុនធី** ជាសាស្ត្រាចារ្យណែនាំ លោកបានខិតខំចំណាយពេលវេលាដើម្បីពន្យល់ណែនាំ ផ្តល់ជាយោបល់ និងការកែតម្រូវ នូវប្រធានបទសារណារបស់យើងខ្ញុំ។
- **ឯកឧត្តម ឈួន សំណាង** ចៅក្រមអមសាលាឧទ្ធរណ៍បានជួយបកស្រាយពន្យល់ឱ្យយើងខ្ញុំបានយល់កាន់តែច្បាស់បន្ថែមលើប្រធានបទនេះ។
- លោកគ្រូសាស្ត្រាចារ្យ **ញឹក ឧុទ្ធី** លោកជាប្រធានការិយាល័យស្រាវជ្រាវ និងព្រមទាំងលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាទីគោរពស្រឡាញ់នៃយើងខ្ញុំ។

# អារម្ភកថា

មនុស្សគ្រប់ៗរូបតែងតែមានបំណងនិងសេចក្ដីប្រាថ្នារៀងៗខ្លួនក្នុងជីវិតរបស់ពួកគេហើយមនុស្សទាំងអស់នោះខ្លះ ទទួលបានភាពជោគជ័យនៅក្នុងជិវិត ហើយខ្លះទៀតក៏ជួបនូវបញ្ហាជាច្រើនដែលធ្វើឱ្យពួកគេបរាជ័យ ដោយសារតែពួកគេទាំងអស់នោះ មិនបានកំណត់អំពីគោលដៅរបស់ពួកគេឱ្យបានច្បាស់លាស់ក្នុងជីវិត។ ដូចគ្នានេះផងដែរចំពោះការសិក្សាដែលទទួលបាននូវភាពជោគជ័យគឺអាស្រ័យទៅលើការកំណត់គោលដៅ និងគោលបំណងច្បាស់លាស់ ការយកចិត្តទុកដាក់ ការបែងចែកពេលវេលាសិក្សាឱ្យបានច្បាស់លាស់ និងមានទំនួលខុសត្រូវលើការសិក្សារបស់ខ្លួន។

ចំពោះប្រធានបទសារណារបស់យើងខ្ញុំទាំងពីរនាក់ ដែលបានជ្រើសយកមកធ្វើការសិក្សាជាកិច្ចការស្រាវជ្រាវនេះគឺស្ដីពី "**ការប្រៀបធៀបបទល្មើសឆបោក និងរំលោភលើទំនុកចិត្ត**" ដែលយើងខ្ញុំមានទំនួលខុសត្រូវនឹងធ្វើការបកស្រាយនូវចំណុចនីមួយៗនៅក្នុងខ្លឹមសារអត្ថបទសារណា របស់យើងខ្ញុំ។ ចំពោះអត្ថបទមួយនេះ ប្រាកដជាមានចំនុចណាមួយខ្វះចន្លោះ ឬ ភ្លេចភ្លាំងដោយប្រការណាមួយនោះ យើងខ្ញុំក៏សូមខន្តី អភ័យទោសទុកជាមុនចំពោះអក្ខរាវិរុទ្ធ អត្ថន័យ ខ្លឹមសារ និងការប្រើប្រាស់ពាក្យពេចន៍ សូមលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និង បងប្អូន មិត្តនិស្សិត ទាំងអស់គ្នាដែលបានអាន ឬ មើលសារណារបស់យើងខ្ញុំ សូមមេត្តាអធ្យាស្រ័យ ដោយក្ដីអនុគ្រោះ។

យើងខ្ញុំសង្ឃឹមផងដែរថា កិច្ចការស្រាវជ្រាវមួយនេះអាចជួយមិត្តនិស្សិត ក៏ដូចជាមិត្តនិស្សិតក្រោយៗទៀតបានសិក្សាឈ្វេងយល់និងអាចវិនិច្ឆ័យរវាងបទល្មើសទាំងពីរនេះឱ្យបានច្បាស់លាស់ ជាងមុន។ ទោះបីជាកិច្ចការស្រាវជ្រាវរបស់យើងខ្ញុំពុំសូវមានលក្ខណៈទូលំទូលាយក៏ដោយ តែវាក៏ជាផ្នែកមួយនៃការដោះស្រាយនូវចំនុចងឿងឆ្ងល់របស់មិត្តនិស្សិតខ្លះៗដែរ។ ហើយយើងខ្ញុំក៏រង់ចាំទទួលយកនូវចំណុចរិះគន់ដើម្បីកែលំអរពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងបងប្អូន មិត្តនិស្សិតទាំងអស់ដែលបានអាន និងសិក្សាអំពីប្រធានបទនេះ ដោយក្ដីគោរពនិងរាប់អាន។


- **លន់ ផល្លី** Tell: ០៦៧ ៧៧៩ ៩១៥, ០៩៦ ៤៧០ ០៥១៥ Email: phallylun6@gmail.com
- **សំ សុផល** Tell: ០៩៣ ៦៣៨ ៩១៧។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១.សញ្ញាណទូទៅនៃបទល្មើស** ........................................ ៤

**ផ្នែកទី១.បទល្មើសឆបោក** ........................................ ៤

**កថាខណ្ឌទី១.និយមន័យនៃបទល្មើសឆបោក** ........................................ ៤

១.ច្បាប់ព្រហ្មទណ្ឌអន្តរកាល ........................................ ៤

២.ក្រមព្រហ្មទណ្ឌបច្ចុប្បន្ន ........................................ ៤

**កថាខណ្ឌទី២.ធាតុផ្សំនៃបទល្មើសឆបោក** ........................................ ៤

១.ធាតុនីត្យានុកូលនៃបទល្មើសឆបោក ........................................ ៥

២.ធាតុសត្យានុម័ត ........................................ ៦

៣.ធាតុអត្តនោម័ត ........................................ ៧

៤.ប្រធាននៃបទល្មើស ........................................ ៧

៤.១.រូបវន្តបុគ្គល ........................................ ៧

៤.១.១រូបវន្តបុគ្គលជាអនីតិជន ........................................ ៨

៤.១.២រូបវន្តបុគ្គលជានីតិជន ........................................ ១០

៤.២នីតិបុគ្គល ........................................ ១២

៤.២.១នីតិបុគ្គលសាធារណៈ ........................................ ១២

៤.២.២នីតិបុគ្គលឯកជន ........................................ ១២

**កថាខណ្ឌទី៣.ជនដែលទទួលខុសត្រូវព្រហ្មទណ្ឌ** ........ ១៣

១.ចារី ........ ១៣

២.សហចារី ........ ១៣

៣.អ្នកផ្តើមគំនិត ........ ១៣

៤.អ្នកសមគំនិត ........ ១៤

**កថាខណ្ឌទី៤.ទោសដែលត្រូវអនុវត្ត** ........ ១៥

១.ទោសធម្មតាចំពោះបទល្មើសឆបោក ........ ១៨

២.ស្ថានទម្ងន់ទោស ........ ១៨

២.១ស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ........ ១៩

២.២ស្ថានទម្ងទោសផ្សេងទៀត ........ ២២

៣.ការប៉ុនប៉ងមានទោស ........ ២៤

៤.ទោសបន្ថែម ........ ២៥

**កថាខណ្ឌទី៥.បទល្មើសប្រហាក់ប្រហែលនឹងបទល្មើសឆបោក** ........ ២៦

១.ការបន្លំ ........ ២៦

២.ការរំលោភលើភាពល្ងង់ខ្លៅ និងបុគ្គលទន់ខ្សោយ ........ ២៦

**ផ្នែកទី២.បទរំលោភលើទំនុកចិត្ត** ........ ២៧

**កថាខណ្ឌទី១.និយមន័យបទល្មើសរំលោភលើទំនុកចិត្ត** ........ ២៧

ក.ច្បាប់ព្រហ្មទណ្ឌអន្តរកាល ........ ២៧

ខ.ក្រមព្រហ្មទណ្ឌបច្ចុប្បន្ន ........ ២៧

**កថាខណ្ឌទី២.ធាតុផ្សំនៃបទល្មើសរំលោភលើទំនុកចិត្ត**...........................................២៨

១.ធាតុនីត្យានុកូលនៃបទរំលោភលើទំនុកចិត្ត ..................................................២៨

២.ធាតុសត្យានុម័តនៃបទរំលោភលើទំនុកចិត្ត ..................................................២៨

២.១ការព្រមព្រៀងប្រគល់វត្ថុរវាងជនរងគ្រោះ និងជនល្មើស ..........................២៨

២.២ជនល្មើសពុំបានបំពេញកាតព្វកិច្ចប្រគល់សងឬប្រើប្រាស់តាមការកំណត់ ៣០

២.៣ជនជាប់ចោទបានបំបាត់ ឬ គៃបន្លំទ្រព្យរបស់ជនរងគ្រោះ ......................៣១

៣.ធាតុអត្តនោម័តនៃបទរំលោភលើទំនុកចិត្ត ..................................................៣៣

៤.ប្រធាននៃបទល្មើស..........................................................................................៣៣

**កថាខណ្ឌទី៣.ជនដែលទទួលខុសត្រូវព្រហ្មទណ្ឌ**..................................................៣៤

១.ចារី..............................................................................................................៣៤

២.សហចារី.......................................................................................................៣៤

៣.អ្នកផ្ដើមគំនិត ............................................................................................ ៣៥

៤.អ្នកសមគំនិត ............................................................................................... ៣៥

**កថាខណ្ឌទី៤.ទោសដែលត្រូវអនុវត្ត**.................................................................... ៣៦

១.ទោសធម្មតា .................................................................................................. ៣៦

២.ស្ថានទម្ងន់ទោស............................................................................................ ៣៦

៣.ទោសបន្ថែម................................................................................................... ៣៨

៤.ការប៉ុនប៉ង .................................................................................................... ៣៨

**កថាខណ្ឌទី៥.បទរំលោភលើទំនុកចិត្តពិសេស**.......................................................៣៩

១.ប្រធាននៃបទរំលោភលើទំនុកចិត្តពិសេស ........ ៤០
២.ទោសដែលត្រូវអនុវត្ត ........ ៤០
**ជំពូកទី២.ការប្រៀបធៀបបទល្មើសទាំងពីរ** ........ ៤១
**ផ្នែកទី១.ចំណុចដូចគ្នារវាងបទល្មើសទាំងពីរ** ........ ៤១
**កថាខណ្ឌទី១.ធាតុនីត្យានុកូល** ........ ៤១
១.ចែងនៅក្នុងគន្ថី ........ ៤១
១.១ចែងនៅក្នុងមាតិកា ........ ៤២
១.២ធាតុនីត្យានុកូលនៃទោស ........ ៤២
១.៣កំណត់ការប៉ុនប៉ងមានទោស ........ ៤២
**កថាខណ្ឌទី២.ចំណាត់ថ្នាក់នៃបទល្មើស** ........ ៤២
**កថាខណ្ឌទី៣.អាជ្ញាយុកាល** ........ ៤៤
១.អាជ្ញាយុកាលនៃបទល្មើស ........ ៤៤
២.អាជ្ញាយុកាលនៃទោស ........ ៤៤
**កថាខណ្ឌទី៤.ធាតុអត្តនោម័ត** ........ ៤៥
**ផ្នែកទី២.ចំណុចខុសគ្នារវាងបទល្មើសទាំងពីរ** ........ ៤៥
**កថាខណ្ឌទី១.ធាតុនីត្យានុកូលនៃបទល្មើសទាំងពីរ** ........ ៤៥
១.និយមន័យនៃបទល្មើស ........ ៤៥
២.ចែងនៅក្នុងមាត្រា ........ ៤៦
៣.ស្ថានទម្ងន់ទោស ........ ៤៦

៤.ទោសបន្ថែម ....................................................................................... ៤៧

៣.ចែងនៅក្នុងជំពូក ..................................................................................... ៤៩

**កថាខណ្ឌទី២.ធាតុសត្យានុម័តនៃបទល្មើសទាំងពីរ** ............................................ ៤៩

១.រូបភាពនៃអំពើ ........................................................................................ ៤៩

២.កម្មវត្ថុនៃបទល្មើស .................................................................................. ៥០

៣.រូបភាពនៃចេតនាប្រព្រឹត្ត ............................................................................ ៥០

**សេចក្តីសន្និដ្ឋាន** ............................................................................................ ៥២

**អនុសាសន៍** .................................................................................................. ៥៤

# សេចក្តីផ្តើម

នៅលើពិភពលោកយើងនេះមានប្រទេសជាច្រើនកំពុងតែរស់នៅប្រកបដោយភាពប្រាស្រ័យទាក់ទងគ្នាតាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន។ ហើយការប្រាស្រ័យទាក់ទងគ្នានេះដែរក៏តែងតែមានបញ្ហាមួយចំនួនបានកើតឡើងទៅលើជនស្លូតត្រង់ដែលត្រូវបានគេរំលោភបំពានសិទ្ធិ។ ហេតុនេះហើយទើបប្រទេសជាច្រើននៅលើសកលលោកក៏ដូចជាព្រះរាជាណាចក្រកម្ពុជាបានខិតខំបង្កើតឱ្យមានច្បាប់ឡើងដើម្បី ការពារសិទ្ធិ និងកាតព្វកិច្ចនានារបស់ប្រជាពលរដ្ឋ និងការគ្រប់គ្រងសណ្តាប់ធ្នាប់សាធារណៈឱ្យបានល្អ និងធានាការពារលើទ្រព្យសម្បត្តិរបស់ជនទូទៅ និងបុគ្គលឯកជនកុំឱ្យមានការបំពានណាមួយដែលមិនត្រឹមត្រូវដោយអំពើអសកម្ម ផ្ទុយពីបទប្បញ្ញត្តិច្បាប់។

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំលើកទី៣ នីតិកាលទី៤ ហើយព្រឹទ្ធសភាបានពិនិត្យ និងយល់ស្របទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២។ ហើយក្រមនេះត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ វិច្ឆិកា ឆ្នាំ២០០៩ មានចំនួន៦ គន្ថី ចែកជា៦៧២មាត្រា។ ក្រមនេះបានចូលជាធរមាននៅរាជធានីភ្នំពេញរយៈពេល ១០ថ្ងៃ បន្ទាប់ពីថ្ងៃប្រកាសឱ្យប្រើ និងទូទាំងប្រទេសរយៈពេល២០ថ្ងៃក្រោយថ្ងៃប្រកាសឱ្យប្រើ។ ហើយ **គន្ថីទី១ ស្តីពីបញ្ញត្តិទូទៅ** នៃក្រមនេះចូលជាធរមានភ្លាមបន្ទាប់ពីប្រកាសឱ្យប្រើមានចំនួន១៨២មាត្រា។ ហើយគន្ថីផ្សេងៗទៀតចូលជាធរមានមួយឆ្នាំក្រោយពេលប្រកាសឱ្យប្រើ។ ក្នុងចំណោមគន្ថីទាំង៦ មានតែ៣គន្ថីប៉ុណ្ណោះ បានកំណត់ពីបទល្មើស និងទោស មាន**គន្ថីទី២ និយាយពីបទល្មើសប្រឆាំងនឹងបុគ្គល គន្ថីទី៣ និយាយពីបទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ និងគន្ថីទី៤ និយាយអំពីបទល្មើសប្រឆាំងនឹងជាតិ**។ ហើយក្រមនេះបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការបង្ការបទល្មើស បង្ក្រាប និងដាក់ទណ្ឌកម្មដល់ជនល្មើសដើម្បីទប់ស្កាត់ ថែរក្សាសណ្តាប់ធ្នាប់សាធារណៈកុំមានការបំពាននានាកើតឡើង។

ដើម្បីយល់ឱ្យកាន់តែច្បាស់ ខ្ញុំសូមធ្វើការពន្យល់ត្រួសៗអំពីបទល្មើស។ បទល្មើស គឺជាអំពើមួយដែលកើតចេញពីការប្រព្រឹត្តរបស់ចារី ដែលអំពើល្មើសទាំងនោះខ្លះកើតចេញពីអំពើចេតនា ឬ អចេតនា ដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ (សុវត្ថិភាព អានាម័យ និងភាពស្ងប់ស្ងាត់) ឬ បំពានសិទ្ធិប្រជាពលរដ្ឋណាមួយដែលនាំឱ្យបាត់បង់នូវផលប្រយោជន៍ ដូចជាទ្រព្យសម្បត្តិ ឬក៏ប៉ះពាល់ដល់រាងកាយ ឬសេចក្តីថ្លៃថ្នូរបស់បុគ្គលដែលជាជនរងគ្រោះជាដើម។ អំពើទាំងនោះបានចែងយ៉ាងច្បាស់នៅក្នុងបទប្បញ្ញត្តិណាមួយដែលកំណត់ថាអំពើទាំងនោះជាបទល្មើសហើយត្រូវផ្តន្ទាទោស។ ហើយការផ្តន្ទាទោសនេះទៀតសោតលុះត្រាតែ ជាអំពើរបស់ចារីផ្ទាល់តែប៉ុណ្ណោះទើបអាចត្រូវប្រកាសបាន ។ បន្ទាប់ពីបានយល់ខ្លះៗពីបទល្មើសហើយ យើងខ្ញុំសូមធ្វើការបកស្រាយខ្លះពីសញ្ញាណទូទៅនៃ**ការឆបោក** គឺតម្រូវឱ្យចារីប្រើប្រាស់នូវមធ្យោបាយមួយចំនួនដោយត្រូវប្រព្រឹត្តក្នុងចេតនាទុច្ចរិត ហើយដោយសារតែមធ្យោបាយទាំងនេះ ចារីបំភាន់បុគ្គលណាម្នាក់ និងញ៉ាំងឱ្យប្រគល់នូវរបស់អ្វីមួយមកខ្លួន។ មធ្យោបាយដែលប្រើប្រាស់ចាំបាច់ ត្រូវតែមាននៅមុនការប្រគល់ ហើយត្រូវតែញ៉ាំងឱ្យមានការប្រគល់នេះ។ វាហាក់ដូចជាមាន ដែលត្រូវគូសបញ្ជាក់ បុគ្គលដែលអាចត្រូវបាន គេនាំឱ្យមានការភាន់ច្រលំ គឺអាចជារូបវន្តបុគ្គល ឬ នីតិបុគ្គល។ **ការរំលោភលើទំនុកចិត្ត** គឺជាអំពើរំលោភដោយចេតនាទុច្ចរិតនេះជាអំពើនៃការប្រកាន់កិរិយាជាកម្មសិទ្ធករដោយបដិសេធមិនព្រមសងវិញ ឬដោយអំពើនៃការចាយខ្ជះខ្ជាយមិនតាមគោលដៅដែលបានកំណត់។

បន្ទាប់ពីបានយល់ខ្លះពីសញ្ញាណនៃបទល្មើសទាំងពីរហើយ យើងសូមធ្វើការបកស្រាយពីដែនកំណត់នៃប្រធានបទស្រាវជ្រាវរបស់យើងខ្ញុំ ពីការប្រៀបធៀប "**បទល្មើសឆបោក និងរំលោភលើទំនុកចិត្ត**" ដែលមានចែងនៅក្នុងគន្ថីទី៣ នៃក្រមព្រហ្មទណ្ឌដែលទាក់ទងទៅនឹងបទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ។ ជាដំបូងយើងខ្ញុំសូមធ្វើការបកស្រាយអំពីសញ្ញាណនៃបទល្មើសទាំងពីរនៅក្នុងជំពូកទី១ និងបែងចែកចេញជាពីរផ្នែក។ ផ្នែកទី១ ៖ និយាយពីបទល្មើសឆបោក និងផ្នែកទី២៖ និយាយពីបទល្មើសរំលោភលើទំនុកចិត្ត។ ចំណែកជំពូកទី២ និយាយពីការប្រៀបធៀបបទល្មើសទាំងពីររវាងបទល្មើសឆបោក និង

រំលោភលើទំនុកចិត្ត ហើយជំពូកទី២ នេះក៏បែងចែកជាពីរដែរ គឺផ្នែកទី១៖ លក្ខណៈដូចគ្នារវាងបទល្មើសឆបោក និងរំលោភលើទំនុកចិត្ត និងផ្នែកទី២៖ នឹងធ្វើការបកស្រាយពីលក្ខណៈខុសគ្នានៃបទល្មើសទាំងពីរ។

# ជំពូកទី១.សញ្ញាណទូទៅនៃបទល្មើស

## ផ្នែកទី១.បទល្មើសឆបោក

### កថាខណ្ឌទី១.និយមន័យនៃបទល្មើសឆបោក

**១.ច្បាប់ព្រហ្មទណ្ឌអន្តរកាល**

ជនណាដែលធ្វើឱ្យគេឱ្យមកខ្លួន ឬប៉ុនប៉ងធ្វើឱ្យគេឱ្យមកខ្លួននូវទ្រព្យសម្បត្តិទាំងអស់ ឬមួយចំណែកនៃទ្រព្យសម្បត្តិរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដោយប្រើល្បិចបន្លំ ឬក្លែងឈ្មោះ ឬក្លែងគុណភាព ដើម្បីបញ្ចុះបញ្ចូលជនរងគ្រោះ ឱ្យជឿតាមអំណាចក្នុងការស្រម៉ៃ ឬ ដោយធ្វើឱ្យជនរងគ្រោះខ្លាច ឬសង្ឃឹមលើព្រឹត្តិការណ៍អ្វីមួយ[1]។

**២.ក្រមព្រហ្មទណ្ឌបច្ចុប្បន្ន**

អំពើឆបោក គឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដោយប្រើឈ្មោះក្លែង ដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនេះ ដែលនាំឱ្យខូចប្រយោជន៍របស់បុគ្គលនេះ ឬរបស់តតិយជននូវ៖

១.ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ។

២.ការផ្គត់ផ្គង់សេវា។

៣.ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចពីកាតព្វកិច្ច[2]។

### កថាខណ្ឌទី២.ធាតុផ្សំនៃបទល្មើសឆបោក

ធាតុផ្សំនៃបទល្មើសនៅក្នុងឯកសារមួយចំនួនមានការបកស្រាយតែបីប៉ុណ្ណោះ តែនៅក្នុងកិច្ចការស្រាវជ្រាវរបស់យើងខ្ញុំសូមលើកយកធាតុផ្សំចំនួនបួនមកធ្វើការបកស្រាយ។ ហើយមុននឹងធ្វើការបកស្រាយនូវធាតុផ្សំទាំងបួននៃបទល្មើស ជាដំបូងយើងខ្ញុំសូមធ្វើការបកស្រាយថាអ្វីដែលហៅថាបទល្មើសព្រហ្មទណ្ឌជាមុនសិន។ បទល្មើសព្រហ្មទណ្ឌ គឺជាអំពើទាំងឡាយណាដែលច្បាប់ព្រហ្មទណ្ឌបានចែងទុកជាមុនថាជាបទល្មើសហើយត្រូវផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌ ហើយអំពើល្មើសទាំងនោះជាកំហុសរបស់ចារីផ្ទាល់។

[1] មាត្រា៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល

[2] មាត្រា៣៧៧ នៃក្រមព្រហ្មទណ្ឌ

ប្រសិនបើច្បាប់ពុំបានចែងថាអំពើណាមួយជាបទល្មើសទេ អំពើនោះមិនត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌឡើយដោយយោងតាមគោលការណ៍នីត្យានុកូលភាពនៃបទល្មើស។[3]

ជាគោលការណ៍បទល្មើសមួយអាចត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌបាន លុះត្រាតែអំពើទាំងនោះបានបំពេញនូវលក្ខខណ្ឌនៃធាតុផ្សំទាំងបួននៃបទល្មើសដែលច្បាប់បានចែងជាមុនសិននោះទើបអាចចាត់ទុកថាជាបទល្មើស ហើយអាចផ្តន្ទាទោសបាន។ **ធាតុផ្សំទាំងនោះមានធាតុនីត្យានុកូលឬធាតុច្បាប់ ធាតុសត្យានុម័ត ឬធាតុសម្ភារៈ ធាតុអត្តនោម័ត ឬធាតុចេតនា និងប្រធាននៃបទល្មើស។**

### ១.ធាតុនីត្យានុកូលនៃបទល្មើសឆបោក

មុននឹងយើងស្វែងយល់ពីគោលការណ៍នីត្យានុកូលភាពនៃបទល្មើសឆបោក យើងត្រូវស្វែងយល់ពីគោលការណ៍នីត្យានុកូលភាពទូទៅជាមុនសិន។ ធាតុនីត្យានុកូលគឺជាធាតុមួយដែលវាទាក់ទងទៅនឹងច្បាប់។ ជាដំបូងបំផុតចាំបាច់ដាច់ខាតត្រូវតែមានច្បាប់ចែងដើម្បីកំណត់អំពើណាមួយជាបទល្មើស នេះជាអ្វីដែលយើងហៅថា**គោលការណ៍នីត្យានុកូលភាព**។ មានន័យថាមានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះមានចែងនៅក្នុងបទប្បញ្ញត្តិជាធរមានប៉ុណ្ណោះទើប ត្រូវផ្តន្ទាទោសបាន។ ហើយមានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន ទើបអាចប្រកាសបាន។

ចំពោះគោលការណ៍នីត្យានុកូលភាពនៃបទល្មើសឆបោកវិញគឺមានចែងនៅក្នុងក្រមព្រហ្មទណ្ឌចាប់ពីមាត្រា៣៧៧ដល់មាត្រា៣៨២។ បើយោងតាមនិយមន័យខាងលើដែលមានចែងនៅក្នុងមាត្រា៣៧៧នោះ អំពើឆបោក គឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដោយប្រើឈ្មោះក្លែងដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនេះ ដែលនាំឱ្យខូចប្រយោជន៍របស់បុគ្គលនេះ ឬរបស់តតិយជននូវ៖

១.ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ។

២.ការផ្តត់ផ្គង់សេវា។

---

[3] មាត្រា៣ នៃក្រមព្រហ្មទណ្ឌ

៣.ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចពីកាតព្វកិច្ច។

ធាតុនីត្យានុកូលនេះគឺ មានន័យថាជនល្មើសធ្វើយ៉ាងណាដើម្បីឱ្យជនរងគ្រោះជឿជាក់នូវមធ្យោបាយទុច្ចរិតរបស់ខ្លួន ហើយជនរងគ្រោះព្រមប្រគល់នូវវត្ថុមានតម្លៃណាមួយដូចដែលបកស្រាយខាងលើ។

ចំពោះបទល្មើសឆបោកនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០០០០០ (មួយលាន) រៀល ទៅ ៦០០០០០០ (ប្រាំមួយលាន) រៀល[4]។ ប្រសិនបើក្នុងករណីមានស្ថានទម្ងន់ទោសណាមួយទៀតនោះទោសកាន់តែធ្ងន់ធ្ងរថែមទៀតទៅតាមអំពើដែលបុគ្គលនោះបានប្រព្រឹត្ត ដូចស្ថានទម្ងន់ទោសដែលទាក់ទងនៅនឹងជនរងគ្រោះ និងស្ថានទម្ងន់ទោសផ្សេងទៀតដូចដែលមានចែងនៅក្នុងមាត្រា៣៨០ នៃក្រមព្រហ្មទណ្ឌនេះខ្ញុំនឹងធ្វើការបកស្រាយនៅកថាខណ្ឌទី៣ ចំណុច២។

**២.ធាតុសត្យានុម័ត**

ធាតុសត្យានុម័តគឺជាធាតុទាំងឡាយណាដែលសម្តែងមកខាងក្រៅឱ្យបុគ្គល ឬតតិយជនមើលឃើញពីសកម្មភាពរបស់បុគ្គលណាមួយបានប្រព្រឹត្តអំពើល្មើសពិតប្រាកដ។ ហើយធាតុសត្យានុម័តរបស់បទល្មើសឆបោកគឺជាសកម្មភាពមួយដែលបង្ហាញឱ្យឃើញពីចរិតលក្ខណៈនៃអំពើដូចជា៖

- ជនល្មើសបានប្រើប្រាស់កលល្បិចដោយទុច្ចរិតទៅលើជនរងគ្រោះ។
- ជនរងគ្រោះបានយល់ព្រមប្រគល់នូវទ្រព្យសម្បត្តិផ្សេងៗឱ្យជនល្មើសដោយសារតែជឿលើល្បិចកលរបស់ជនល្មើស។
- ជនរងគ្រោះមានការខូចខាត ឬ ព្យសនកម្ម។[5]

រូបភាពនៃបទល្មើសគឺ ជាសកម្មភាពមួយដែលជនរងគ្រោះបានព្រមព្រៀងប្រគល់នូវទ្រព្យសម្បត្តិណាមួយដែលមានតម្លៃ ដូចជាការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ការផ្គត់ផ្គង់សេវា និងការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬ ឱ្យរួចពី

[4] មាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ

[5] នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុណ ពណ្ណារិទ្ធ និង អ្នកគ្រូសាស្ត្រាចារ្យ ចាំង ស៊ីណាត

កាតព្វកិច្ច ដោយមធ្យោបាយទុច្ចរិតរបស់ជនល្មើសដែលបានអះអាងអំពីឋានៈក្លែងដោយរំលោភទៅលើឋានៈពិតប្រាកដ។

**ឧទាហរណ៍៖** ជនម្នាក់ឈ្មោះ A បានអះអាងថាខ្លួនជាប្រធានក្រុមហ៊ុនមួយដែលអាចជួយរត់ការឱ្យពលករទៅធ្វើការប្រទេសថៃបាន។ ឃើញដូច្នេះ បុរសជាច្រើននាក់ដែលមានបំណងទៅធ្វើការនៅក្រៅប្រទេសផងនោះ ក៏បានប្រគល់ប្រាក់មួយចំនួន ឱ្យទៅជនម្នាក់ឈ្មោះ A ដើម្បីបំពេញការងារនេះ។ តែបុគ្គលនេះមិនមែនជាប្រធានក្រុមហ៊ុនស្អីនោះទេ បន្ទាប់ពីបានលុយពីជនរងគ្រោះហើយ បុគ្គលនោះក៏រត់គេចខ្លួនបាត់។

**៣.ធាតុអត្តនោម័ត**

ជាគោលការណ៍ពុំមានបទល្មើសទេប្រសិនបើគ្មានចេតនាប្រព្រឹត្ត ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកជាមុន បទល្មើសមួយអាចកើតឡើងដោយការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ការមិនគោរពកាតព្វកិច្ចណាមួយដែលច្បាប់តម្រូវ។[6] ចំពោះបទល្មើសឆបោកនេះធាតុចេតនាក្នុងការប្រព្រឹត្តរបស់ជនល្មើសគឺ ជនល្មើសបានប្រើមធ្យោបាយគ្រប់បែបយ៉ាងធ្វើឱ្យជនរងគ្រោះជឿជាក់ និងព្រមប្រគល់នូវទ្រព្យសម្បត្តិ ឬការផ្តត់ផ្គង់សេវា ឬការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬរួចពីកាតព្វកិច្ច ដោយប្រើនូវល្បិចកលណាមួយដោយប្រើនូវឋានៈក្លែង ដោយរំលោភទៅលើឋានៈពិត។ គឺមានន័យថាជនល្មើសបានប្រើនូវល្បិចកលណាមួយដើម្បីឱ្យជនរងគ្រោះជឿជាក់នូវការអះអាងរបស់ខ្លួន ហើយព្រមប្រគល់នូវរបស់អ្វីមួយដែលមានតម្លៃមកឱ្យខ្លួន ដោយជនរងគ្រោះសង្ឃឹមលើព្រឹត្តការណ៍អ្វីមួយ ឬទទួលបានអ្វីមួយពីជនល្មើស។

**៤.ប្រធាននៃបទល្មើស**

ជាគោលការណ៍រាល់បុគ្គលទាំងអស់ដែលបានប្រព្រឹត្តបទល្មើសមិនមែនសុទ្ធតែត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌទាំងអស់នោះទេ។ ចំពោះបុគ្គលមួយចំនួនដែលបានប្រព្រឹត្តបទល្មើស តែមិនត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌឡើយ។ ហើយប្រធាននៃបទល្មើសត្រូវបានចែកជាពីរគឺរូបវន្តបុគ្គល និងនីតិបុគ្គល។

**៤.១.រូបវន្តបុគ្គល**

[6] មាត្រា៤ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា

រូបវន្តបុគ្គល គឺបុគ្គលទាំងឡាយណាដែលកើតមកហើយមានសាច់ ឈាម ហើយមានជីវិតរស់នៅ និងត្រូវបានការពារដោយច្បាប់។ រូបវន្តបុគ្គលនេះត្រូវបានបែងចែកជាពីរទៀតគឺ រូបវន្តបុគ្គលជានីតិជន និងរូបវន្តបុគ្គលជាអនីតិជន។ ដើម្បីឱ្យបុគ្គលណាមួយទទួលខុសត្រូវព្រហ្មទណ្ឌបាននោះ គឺត្រូវតែជាអំពើរបស់ចារីផ្ទាល់។ មានន័យថាអ្នកណាប្រព្រឹត្តអំពើល្មើស អ្នកនោះជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ ពុំមាននរណាម្នាក់អាចទទួលទោសជំនួសជនបង្កបានឡើយ នេះជាគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។[7]

ដើម្បីឱ្យរូបវន្តបុគ្គលដែលជាជនបង្កប្រព្រឹត្តបទល្មើសទទួលខុសត្រូវព្រហ្មទណ្ឌទៅតាមអំពើដែលខ្លួនបានប្រព្រឹត្តត្រូវតែគោរពនូវលក្ខខណ្ឌមួយចំនួនៈ

១.ជនល្មើសត្រូវជាមនុស្ស

២.ជនល្មើសត្រូវតែនៅមានជីវិត

៣.ជនល្មើសមិនមែនជាជនវិកលចរិក ឬ វិបល្លាសស្មារតី

៤.ជនល្មើសត្រូវតែជាជនដែលមានអាយុ១៨ឆ្នាំឡើងទៅ។

**៤.១.១រូបវន្តបុគ្គលជាអនីតិជន**

ដោយផ្អែកទៅលើមូលដ្ឋាននៃការទទួលខុសត្រូវព្រហ្មទណ្ឌ អាយុអាចជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌបាន។ នៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារបានចែងក្នុងមាត្រា៤០នៃអនុសញ្ញាស្តីពីសិទ្ធិកុមារនេះ ចំណុចទី៣ កថាខណ្ឌ ក បានតម្រូវឱ្យរដ្ឋជាភាគីដែលក្នុងនោះក៏មានព្រះរាជាណាចក្រកម្ពុជាផងដែរ បានធ្វើការកំណត់កម្រិតអាយុតិចបំផុតមួយដែលក្រោមនេះ កុមារត្រូវចាត់ទុកថាមិនមានសមត្ថភាពនឹងអាចប្រព្រឹត្តបទល្មើសបានទេ[8]។ ប៉ុន្តែក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់យ៉ាងច្បាស់អំពីជនដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌក៏បានកំណត់អាយុចាប់ពី១៨ឆ្នាំឡើងទៅ[9]។ តែទោះជាយ៉ាងណាក៏ដោយក្រមព្រហ្មទណ្ឌ

[7] មាត្រា២៤ នៃក្រមព្រហ្មទណ្ឌ

[8] នីតិព្រហ្មទណ្ឌទូទៅ ទំព័រ១៦០ រៀបរៀងដោយ សាស្ត្រាចារ្យរុន ពណ្ណារិទ្ធិ ឆ្នាំ២០០៤

[9] មាត្រា៣៨ នៃក្រមព្រហ្មទណ្ឌ

បានចែងបន្ថែមទៀតថា ក្នុងករណីអនីតិជននោះអាយុចាប់ពី១៨ឆ្នាំឡើងទៅ តុលាការអាចប្រកាសទោសព្រហ្មទណ្ឌទៅលើអនីតិជននោះបាន[10]។ មានន័យថាអនីតិជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងគឺត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើល្មើសរបស់ខ្លួនដែលបានប្រព្រឹត្ត តែក្នុងករណី អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ អនីតិជននោះមិនអាចទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ ហើយក៏មិនត្រូវចាប់ខ្លួន ឬក៏ឃុំខ្លួនជាបណ្តោះអាសន្នណាមួយឡើយ។ តុលាការត្រូវមានវិធានការមួយចំនួនចំពោះអនីតិជនដែលបានប្រព្រឹត្តបទល្មើស ត្រូវដាក់ ឱ្យស្ថិតនៅក្រោមការតាមដាន វិធានការការពារ វិធានការឧបត្ថម្ភ វិធានការអប់រំ ពីសំណាក់ស្ថាប័ន តុលាការ[11]។

**វិធានការដែលត្រូវអនុវត្តចំពោះអនីតិជនអាយុក្រោម១៨ឆ្នាំ៖**

១. ប្រគល់អនីតិជនឱ្យទៅអាណាព្យាបាល ឬបុគ្គលដែលមើលថែអនីតិជននោះ ឬជនផ្សេងទៀតប្រសិនបើបុគ្គលនោះស័ក្តិសមនឹងមានទំនុកចិត្តអាចមើលថែ និងអប់រំអនីតិជននោះឱ្យល្អឡើងវិញបាន។

២. ប្រគល់អនីតិជននោះទៅឱ្យសេវាសាធារណៈ ដែលទទួលបន្ទុកក្នុងការមើលថែអប់រំអនីតិជន។

៣. ប្រគល់អនីតិជននោះទៅឱ្យអង្គការឯកជនណាមួយដែលមានសម្បទាអាចមើលថែ និងអប់រំអនីតិជននោះបានល្អ។

ចំណែកឯស្ថានភាពក្នុងកាលៈទេសៈ ឬក៏បុគ្គលិកលក្ខណៈ ឬស្ថានភាពនៃចរិតលក្ខណៈនៃអំពើនោះធ្ងន់ធ្ងរតុលាការត្រូវធ្វើការប្រកាសទោសចំពោះអនីតិជនដែលប្រព្រឹត្តបទល្មើសមានអាយុចាប់ពី១៤ឆ្នាំ ដល់ក្រោម១៨ឆ្នាំ។ តែក្នុងការប្រកាសទោសនេះមិនដូចជាការប្រកាសទោសចំពោះនីតិជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅនោះទេ គឺត្រូវធ្វើការបន្ថយមូលទោសដែលមានចែងក្នុងច្បាប់នោះមកនៅត្រឹមពាក់កណ្តាលនៃមូលទោសតែប៉ុណ្ណោះ[12]។

[10] មាត្រា៣៩ នៃក្រមព្រហ្មទណ្ឌ

[11] សៀវភៅទោសព្រហ្មទណ្ឌសាស្ត្រាចារ្យ កៅ សីហា ទំព័រ១៦៩

[12] មាត្រា១៦០ កថាខណ្ឌទី១ និងទី៤ នៃក្រមព្រហ្មទណ្ឌ

**ឧទាហរណ៍:** **ក** ជាអនីតិជនដែលមានអាយុ ១៧ឆ្នាំបានប្រាប់ទៅបុរស **ខ** ថាខ្លួនជាជំនួយការរបស់ប្រធានក្រុមហ៊ុនមួយនាំពលករទៅធ្វើការនៅប្រទេសជប៉ុន។ ហើយពេលនោះបុរស **ខ** ដែលមានបំណងចង់ទៅធ្វើការប្រទេសជប៉ុនផងនោះ ក៏បានជឿទុកចិត្ត។ ហើយ **ខ** ក៏បានប្រគល់លុយចំនួន១៥០០ដុល្លារឱ្យ **ក** ដើម្បីឱ្យ **ក** រៀបចំឯកសារដើម្បីឱ្យខ្លួនអាចទៅធ្វើការនៅប្រទេសក្រៅបានដូចដែល **ក** បានពន្យល់ប្រាប់នោះ។ បន្ទាប់ពី **ក** បានលុយពី **ខ** ហើយ ក៏បានរត់គេចខ្លួនបាត់។

ក្នុងករណីនេះ **ក** គឺបានប្រព្រឹត្តបទល្មើសមួយដែលមានឈ្មោះថាបទល្មើស ឆបោកហើយត្រូវផ្តន្ទាទោសតាមមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។ ដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣(បី) ឆ្នាំ និងពិន័យជាប្រាក់ ពី១០០០០០០ (មួយលាន)រៀល ទៅ ៦០០០០០០(ប្រាំមួយលាន)រៀល។ តែទោសនេះមិនអាចយកទៅប្រកាសចំពោះអនីតិជននេះតែម្តងបានទេ តុលាការត្រូវធ្វើការបែងចែកទោសនេះជាពីរសិន។ មានន័យថាទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់ត្រូវចែកជាពីរទាំង អតិបរមា និងអប្បបរមា បើដាក់ពន្ធនាគារអប្បបរមាចំនួន ៦ខែ ត្រូវបន្ថយមកនៅត្រឹម ៣ខែ ហើយអតិបរមាចំនួន៣ឆ្នាំ ត្រូវមកនៅត្រឹម ១ឆ្នាំ ៦ខែ តែបើដាក់ពន្ធនាគារអស់មួយជីវិតត្រូវបន្ថយមកនៅត្រឹម២០ឆ្នាំ ប្រសិនបើអតិបរមាដាក់ពន្ធនាគារលើសពី១ថ្ងៃត្រូវបន្ថយពាក់កណ្តាល ចំណែកទោសពិន័យជាប្រាក់ក៏ត្រូវបន្ថយពាក់កណ្តាលដូចគ្នា ។ ដូច្នេះតុលាការអាចធ្វើការប្រកាសទោសចំពោះបទល្មើសឆបោកសម្រាប់អនីតិជននេះគឺទោសដាក់ពន្ធនាគារពី ៣ខែ ទៅ ១ឆ្នាំ ៦ខែ ហើយ និងពិន័យជាប្រាក់ពី ៥០០.០០០(ប្រាំសែន)រៀល ទៅ ១.៥០០.០០០ (មួយលានប្រាំសែន)រៀល[13]។ ក្នុងករណីអនីតិជនដែលបានប្រព្រឹត្តបទល្មើសនោះគឺជាជនដែលមានអាយុក្រោម ១៤ឆ្នាំ អនីតិជននោះមិនអាចត្រូវបានធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌឡើយ។

**៤.១.២រូបវន្តបុគ្គលជានីតិជន**

នីតិជនគឺជាជនដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ ឬតាមន័យម្យ៉ាងទៀតគឺ

[13] សៀវភៅទោសព្រហ្មទណ្ឌ សាស្ត្រាចារ្យច្បាប់ កៅ សីហា ទំព័រ៤៧-៥៣

ជាបុគ្គលដែលមានអាយុគ្រប់តាមការកំណត់របស់ច្បាប់ហើយមានសមត្ថភាព។[14] ចំណែកឯក្រមព្រហ្មទណ្ឌវិញបានកំណត់ថានីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវកំណត់អាយុចាប់ពី១៨ឆ្នាំឡើងទៅ[15]។ ដូច្នេះមានន័យថារាល់បុគ្គលទាំងឡាយណាដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅគឺ ច្បាប់បានចាត់ទុកបុគ្គល ឬជននោះជានីតិជនហើយ។ ដើម្បីឱ្យនីតិជននោះទទួលខុសត្រូវព្រហ្មទណ្ឌបាន លុះត្រាតែបុគ្គលនោះជាអ្នកប្រព្រឹត្តអំពើល្មើសនោះដោយផ្ទាល់ទើបអាចត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌបាន។ ក្នុងករណីនេះវាផ្ទុយពីអំពើល្មើសផ្នែករដ្ឋប្បវេណី ដែលអនុញ្ញាតឱ្យអ្នកដទៃទទួលខុសត្រូវចំពោះអំពើល្មើសរបស់ចារី ឬជនបង្កបាន[16]។

ហើយក្នុងន័យនេះមិនមែនសុទ្ធតែនីតិជនទាំងអស់ដែលបានប្រព្រឹត្តបទល្មើសសុទ្ធតែត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌទាំងអស់នោះទេ ។ បុគ្គលមួយចំនួនដែលមានអាយុ១៨ឆ្នាំ ឬជានីតិជន ប៉ុន្តែក្រមព្រហ្មទណ្ឌមិនអនុញ្ញាតឱ្យធ្វើការផ្តន្ទាទោសជននោះឡើយដោយសារតែបុគ្គលនោះច្បាប់មិនអនុញ្ញាតឱ្យតុលាការធ្វើការប្រកាសទោសបាន។

ដូចជាជនវិបល្លាសស្មារតី គឺជាជនដែលមានវិបត្តិ ដែលធ្វើឱ្យមានភាពរឹករវសកម្មភាពនៃសរសៃប្រសាទរបស់ជននោះ ដែលធ្វើឱ្យមនុស្សបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន។

ឧទាហរណ៍៖ បុរសម្នាក់បានដើរតាមដងផ្លូវ ហើយក៏បានរើសដំបងដែលគេឃើញនៅតាមផ្លូវ ទៅវាយកំទេចឡានរបស់លោក ក ដែលចតនៅមុខផ្ទះរបស់គាត់បណ្តាលឱ្យខូចផ្នែកខាងមុខ។ ហើយបុរស ក បានប្តឹងទៅសមត្ថកិច្ចឱ្យឃាត់ខ្លួនជនបង្កនោះពីបទធ្វើឱ្យខូចខាតដោយចេតនាដែលមានចែងនៅក្នុងមាត្រា៤១០នៃក្រមព្រហ្មទណ្ឌ។ តែក្រោយពីឃាត់ខ្លួនជនបង្កនោះមន្ត្រីនគរបាលក៏ដឹងថាជនបង្កនោះជាជនដែលមានបញ្ហាផ្នែកស្មារតី ឬជាជនវិបល្លាសស្មារតី ដោយមានលិខិតបញ្ជាក់ពីវេជ្ជបណ្ឌិតជំនាញ ពេល

[14] សន្ធានុក្រមផ្នែករដ្ឋប្បវេណី

[15] មាត្រា៣៨ នៃក្រមព្រហ្មទណ្ឌ

[16] មាត្រា៧៤៦-៧៤៧ នៃក្រមរដ្ឋប្បវេណី

នោះមន្ត្រីនគរបាលក៏បានដោះលែងជននោះវិញភ្លាមៗដោយសារតែតុលាការមិនអាចធ្វើការចោទប្រកាន់ជនដែលមិនដឹងខុសត្រូវនោះទេ(ជនវិបល្លាសស្មារតី)[17]។

ហើយនៅក្នុងករណីមួយចំនួនទៀតក៏ច្បាប់មិនអនុញ្ញាតឱ្យតុលាការប្រកាសទោសចំពោះនីតិជនដែលបានប្រព្រឹត្តបទល្មើស ទោះបីជាបទល្មើសនោះមានធាតុផ្សំគ្រប់គ្រាន់ក៏ដោយ ក៏តុលាការមិនអាចប្រកាសទោសជំពោះជនល្មើសនោះបានឡើយ។ ហើយអំពើទាំងនោះរួមមាន ការការពារស្របច្បាប់ សច្ចាធារណ៍នៃការការពារស្របច្បាប់ ស្ថានភាពចាំបាច់ អានុភាពនៃកម្លាំង ឬការបង្ខំ។[18]

**៤.២នីតិបុគ្គល**

នីតិបុគ្គល គឺជាបណ្តុំនៃរូបវន្តបុគ្គល បណ្តុំនៃមនុស្ស ឬមូលនិធិ ដែលត្រូវមានបុគ្គលភាពគតិយុត្តហើយជាម្ចាស់ ឬប្រធាននៃសិទ្ធិ និងកាតព្វកិច្ច។ ហើយនីតិបុគ្គលនេះត្រូវបានគេបែងចែកជាពីរមាន៖

**៤.២.១នីតិបុគ្គលសាធារណៈ**

នីតិបុគ្គលសាធារណៈគឺស្ថាប័នមួយដែលត្រូវបានកំណត់ដោយបទដ្ឋានគតិយុត្តហើយដំណើរការប្រព្រឹត្តទៅរបស់នីតិបុគ្គលសាធារណៈ គឺដើម្បីបម្រើផលប្រយោជន៍សាធារណៈដែលមិនស្វែងរកប្រាក់ចំណេញនោះទេ។[19]

ឧទាហរណ៍៖ រដ្ឋ សមូហភាពដែនដី (រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងគ្រឹះស្ថានសាធាណៈ ( EPA et EPIC)។

**៤.២.២នីតិបុគ្គលឯកជន**

គឺជាបណ្តុំនៃបុគ្គលឯកជនដែលរួមគ្នាបង្កើតឡើងដើម្បីស្វែងរកប្រាក់ចំណេញ ឬមិនស្វែងរកប្រាក់ចំណេញ ហើយការបង្កើតនេះទៀតសោតត្រូវគោរពទៅតាមច្បាប់កំណត់។

[17] មាត្រា៣១ នៃក្រមព្រហ្មទណ្ឌ

[18] មាត្រា៣៣-៣៦នៃក្រមព្រហ្មទណ្ឌ

[19] សៀវភៅនីតិរដ្ឋបាលទូទៅសាស្ត្រាចារ្យហៀង សាង

ឧទាហរណ៍៖ ក្រុមហ៊ុន សហគ្រាស សហជីព សហគមន៍ ឬភ្នាក់ងារសមាគម អង្គការក្រៅរដ្ឋាភិបាល(NGO)...។

**កថាខណ្ឌទី៣.ជនដែលទទួលខុសត្រូវព្រហ្មទណ្ឌ**

**១.ចារី**

ចារីគឺ ជាបុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ ហើយត្រូវចោទប្រកាន់។ ត្រូវចាត់ទុកជាចារីផងដែរ ចំពោះជនដែលបានប៉ុនប៉ងប្រព្រឹត្តបទល្មើស។[20]

ឧទាហរណ៍៖ ១. លោក ក បានទៅសម្លាប់មនុស្សដើម្បីប្លន់យកទ្រព្យសម្បត្តិរបស់អ្នកដទៃ ។ ដូច្នេះលោក ក គឺជាចារីដែលបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ដៃ ព្រោះ លោក ក បានសម្លាប់ និងប្លន់យកទ្រព្យសម្បត្តិអ្នកដទៃ។

២. លោក ក បានទៅគាស់ផ្ទះរបស់ប្រជាពលរដ្ឋនៅពេលយប់ដើម្បីចូលលួចទ្រព្យសម្បត្តិក្នុងផ្ទះ តែកំពុងគាស់ទ្វារ ស្រាប់តែម្ចាស់ផ្ទះមកទាន់។ ដូច្នេះអំពើរបស់ ក គឺជាការប៉ុនប៉ងប្រព្រឹត្តបទល្មើសលួច ដូច្នេះអំពើរបស់លោក ក ក៏ត្រូវចាត់ទុកជាចារីដែរ។

**២.សហចារី**

ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់។

ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក។[21]

ឧទាហរណ៍៖ ១. ក ខ និង គ បានព្រមព្រៀងគ្នាទៅវាយកម្ទេចរថយន្តរបស់គេដែលចតទុកមុខផ្ទះរបស់ខ្លួន ដូច្នេះអំពើរបស់ ក ខ និង គ គឺជាសហចារី។

**៣.អ្នកផ្តើមគំនិត**

ត្រូវចាត់ទុកជាអ្នកផ្តើមគំនិតក្នុងបទឧក្រិដ្ឋ ឬ មជ្ឈិមចំពោះបុគ្គលណា៖

- ជម្រុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះតាមការណែនាំ ឬការបញ្ជា។

[20] មាត្រា២៥ នៃក្រមព្រហ្មទណ្ឌ

[21] មាត្រា២៦ នៃក្រមព្រហ្មទណ្ឌ

- បង្កឱ្យមានបទឧក្រិដ្ឋ ឬមជ្ឈិមនោះ ដោយផ្តល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬ ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។

អ្នកផ្តើមគំនិតអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬ បទមជ្ឈិមត្រូវសម្រេច ឬ ប៉ុនប៉ង។ អ្នកផ្តើមគំនិតត្រូវផ្តន្ទាទោសដូចគ្នានឹងអ្នកប្រព្រឹត្តបទល្មើសដែរ។

ឧទាហរណ៍៖ លោក ក បានបញ្ជាលោក គ ឱ្យទៅសម្លាប់មនុស្ស។ តែប្រសិនបើលោក គ មិនបានទៅសម្លាប់មនុស្សទេ អំពើចំបងនេះពុំមានទោសទេ ព្រោះមិនមានបទល្មើសកើតឡើង ។ ហេតុដូច្នេះ អ្នកផ្តើមគំនិតក៏ពុំមានទោសដែរ។ ក្នុងករណីនេះអំពើរបស់លោក ក ពុំមែនជាការផ្តើមគំនិតដែលត្រូវផ្តន្ទាទោសបានទេ តែអំពើនេះត្រូវផ្តន្ទាទោសក្រោមឈ្មោះបទល្មើសផ្សេង គឺបទញុះញង់ដែលមានចែងនៅមាត្រា៤៩៤ ហើយនឹងត្រូវផ្តន្ទាទោសតាម៤៩៥ នៃក្រមព្រហ្មទណ្ឌ។

- **ធាតុផ្សំសត្យានុម័តនៃការផ្តើមគំនិត៖** សំដៅលើការជំរុញណែនាំ ឬបញ្ជា ដោយការបង្ក ដោយផ្តល់អំណោយ ដោយការសន្យា ឬ ការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។
- **ធាតុអត្តនោម័តនៃការផ្តើមគំនិត៖** អ្នកផ្តើមគំនិតមានបំណងប្រព្រឹត្តអំពើ ផ្តើមគំនិតមានន័យថា អ្នកផ្តើមគំនិតដឹងថា អំពើរបស់ចារីគឺ ជាបទល្មើស ហើយខ្លួននៅតែមានចេតនាផ្តើមគំនិតឱ្យបទល្មើសនេះកើតមានទៀត។[22]

**៤.អ្នកសមគំនិត**

អ្នកសមគំនិត សំដៅលើបុគ្គលណាដែលជួយសម្រួលដោយចេតនា ដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។ ក្នុង

[22] ឯកសារសិក្ខាសាលានីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ រៀបរាងដោយ សាស្ត្រាវុណ្ណារិទ្ធិ និងអ្នកគ្រូសាស្ត្រា ថាំង ស៊ី ណាត ទំព័រ១០៩

លក្ខណៈប្រហាក់ប្រហែលនឹងការផ្តើមគំនិតដែរ ការសមគំនិតត្រូវបំពេញលក្ខខណ្ឌបីយ៉ាង ដើម្បីអាចផ្តន្ទាទោសបានគឺ៖[23]

- អំពើចម្បងមានទោស
- ធាតុសត្យានុម័តៈ ការផ្តល់ជំនួយ ឬឧបត្ថម្ភ
- ធាតុអត្តនោម័តៈ អ្នកសមគំនិតដឹងថា អំពើរបស់ចារីជាបទល្មើស ហើយខ្លួននៅតែមានចេតនាផ្តល់ជំនួយ ឬឧបត្ថម្ភទៀត។

**កថាខណ្ឌទី៤.ទោសដែលត្រូវអនុវត្ត**

មុននឹងយើងយល់នូវទោសដែលត្រូវអនុវត្តយើងត្រូវយល់នូវអ្វីដែលហៅថាទោសព្រហ្មទណ្ឌជាមុនសិន។ ហើយទោសព្រហ្មទណ្ឌនេះយើងសូមលើកយកពីរទស្សនៈមកបកស្រាយបង្ហាញជូន៖

**តាមបែបទស្សនៈវិជ្ជា** ទោសព្រហ្មទណ្ឌ គឺជាប្រតិកម្មរបស់សង្គម ឬក៏ជាការឆ្លើយតបរបស់សង្គមទៅនឹងអ្នកប្រព្រឹត្តបទល្មើសបានន័យថា ប្រឆាំងជាមួយចារីនៃបទល្មើស។ ហើយបទល្មើសនេះហើយជាអំពើដែលប្រឆាំងនឹងរដ្ឋ អំពើដែលនាំឱ្យមានគ្រោះថ្នាក់ដល់សង្គម អំពើប្រឆាំងនឹងច្បាប់ព្រហ្មទណ្ឌជាធរមាន និងត្រូវផ្តន្ទាទោស។[24]

**ទស្សនៈតាមបែបនីតិសាស្ត្រ** ទោសព្រហ្មទណ្ឌ គឺជាទោសដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌហើយដែលត្រូវប្រកាសដោយតុលាការព្រហ្មទណ្ឌ។[25]

ទោសព្រហ្មទណ្ឌត្រូវបាននីតិករបែងចែកជាបីប្រភេទ គឺមូលទោស ទោសបន្ថែម និងទោសជំនួស។

➢ **មូលទោស** គឺជាទោសមូលដ្ឋានដែលមានចែងនៅក្នុងបទប្បញ្ញត្តិនៃមាត្រានីមួយៗ ហើយយកទៅប្រើប្រាស់សម្រាប់ការប្រកាសទោសចំពោះជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើស។ មូលទោសមានទោស

[23] ឯកសារសិក្ខាសាលានីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ រៀបរាងដោយ សាស្ត្រាវុណ្ណារិទ្ធិ និងអ្នកគ្រូសាស្ត្រា ចាំង ស៊ី ណាត ទំព័រ១០៩

[24] សៀវភៅទោសព្រហ្មទណ្ឌ សាស្ត្រាចារ្យ កៅ សីហា ទំព័រ១១

[25] សៀវភៅទោសព្រហ្មទណ្ឌ សាស្ត្រាចារ្យ កៅ សីហា ទំព័រ១១

ពន្ធនាគារ និងទោសពិន័យជាប្រាក់។[26] ចំណែកឯទោសប្រហារជីវិតត្រូវបានលុបបំបាត់ដោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។[27]

ទោសដាក់ពន្ធនាគារគឺជាទោសបំបាត់សេរីភាពមានកំណត់កាល ហើយនៅក្នុងការដាក់ពន្ធនាគារនេះទៀត ច្បាប់ចែងកំណត់ពីអប្បបរិមា និងអតិបរមានៃទោស។ ទោសដាក់ពន្ធនាគារអាចជាទោសដាក់ពន្ធនាគារអស់មួយជីវិត ឬមានកំណត់រយៈពេលដែលអតិបរមាគឺមាន៣០ឆ្នាំ។[28]

- **ទោសបន្ថែម** គឺជាទោសក្រៅពីទោសមូលដ្ឋាន ឬក៏ជាមូលទោសដែលមានដូចទោសដាក់ពន្ធនាគារ ឬ ទោសពិន័យជាប្រាក់ហើយតុលាការអាចធ្វើការសម្រេចពិចារណាអំពីទោសបន្ថែម ដែលអាចប្រកាសចំពោះ ទណ្ឌិតនោះបន្ថែមបាន។ ទោសបន្ថែមអាចប្រកាសទៅបាន លុះត្រាតែមានច្បាប់ចែងយ៉ាងច្បាស់ចំពោះបទល្មើសដែលត្រូវបានចោទប្រកាន់។[29] ហើយទោសបន្ថែមនេះសំដៅទៅលើទោសមួយ ដែលបន្ថែមទៅលើមូលទោស មានន័យថាជាទូទៅនៅពេលដែលចៅក្រមគាត់ប្រកាសអំពីមូលទោស ហើយក្នុងករណីដែលមានលក្ខខណ្ឌច្បាប់ចែងកំណត់អនុញ្ញាតឱ្យផ្តន្ទាទោស ទោសបន្ថែមនោះទើបចៅក្រមមានសិទ្ធិសម្រេច បន្ថែមទោសនោះទៅលើមូលទោសបាន។ ហើយទោសបន្ថែមនេះមានចំនួន១៩ចំណុចសម្រាប់នីតិជន។[30] ម្យ៉ាងវិញទៀតទោសបន្ថែមនេះចៅក្រមអាចធ្វើការសម្រេចប្រកាសជំនួសមូលទោសបានដោយទោសបន្ថែមមួយ ឬច្រើនបាន។[31]

---

[26] មាត្រា៥៣ នៃក្រមព្រហ្មទណ្ឌ

[27] មាត្រា៣២ នៃរដ្ឋធម្មនុញ្ញ

[28] សិក្ខាសាលាស្តីពី នីតិព្រហ្មទណ្ឌនិង នីតិគ្រួសារ រៀបរៀងដោយ រុន ពណ្ណារិទ្ធ &លោកស្រីសាស្ត្រាចារ្យ ចាំង សីណាត

[29] សៀវភៅទោសព្រហ្មទណ្ឌ សាស្ត្រាចារ្យ កៅ សីហា ទំព័រ៦៦

[30] មាត្រា៥៣ នៃក្រមព្រហ្មទណ្ឌ

[31] មាត្រា១០០ នៃក្រមព្រហ្មទណ្ឌ

- **ទោសជំនួស** គឺជាទោសមួយដែលអាចឱ្យតុលាការយកមកប្រើប្រាស់ជំនួសមូលទោសចំពោះការប្រព្រឹត្តបទល្មើសណាមួយ ដូចជាទោសការងារសហគមន៍ ឬការស្តីបន្ទោសដែលត្រូវបានកំណត់ជាជំនួសទោសដាក់ពន្ធនាគារ

1. **ទោសការងារសហគមន៍** គឺជាទោសជំនួសមួយប្រភេទ ដែលតម្រូវឱ្យទណ្ឌិតបំពេញការងារក្នុងចិរវេលាចន្លោះពី ៣០ម៉ោង ទៅ២០០ ម៉ោង ដោយគ្មានកម្រៃដើម្បីជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងៗទៀត ដល់សមាគម ឬដល់អង្គការមិនមែនរដ្ឋាភិបាល។[32] តុលាការ អាចប្រកាសទោសការងារសហគមន៍បាន បើកាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមាតិចជាង ឬស្មើនឹង៣ឆ្នាំ។[33]
2. **ទោសស្តីបន្ទោស** គឺទោសដែលប្រើប្រាស់សម្រាប់ទោសស្រាលដូចជាបទលហុជាដើម ហើយចៅក្រមគាត់មិនសម្រេចដាក់ពន្ធនាគារ ឬពិន័យជាប្រាក់នោះទេ ប៉ុន្តែចៅក្រមសម្រេចប្រកាសទោសនេះបាន ព្រោះទោសស្តីបន្ទោសនេះគឺជាទោសព្រមាន ការប្រដៅអំពីទោសកំហុសឆ្គងដែលជនល្មើសបានប្រព្រឹត្ត ហើយជាការព្រមានថា កុំឱ្យជនបង្កគាត់ប្រព្រឹត្តម្តងទៀត ឬបទល្មើសថ្មីទៀត ហើយទោសនេះភាគច្រើនប្រកាសចំពោះតែ អនីតិជនដែលមានអាយុក្រោម១៨ឆ្នាំ មកដល់ត្រឹម១៤ឆ្នាំ។[34] របបនៃការប្រកាសទោសចំពោះទោសស្តីបន្ទោសនេះកាលបើជនជាប់ចោទរងទោសពន្ធនាគារដែលអតិបរមាតិចជាង ឬស្មើនឹង៣ឆ្នាំ តុលាការ

[32] សៀវភៅទោសព្រហ្មទណ្ឌ សាស្ត្រាចារ្យ កៅ សីហា ទំព័រ១០៦

[33] មាត្រា៧២ នៃក្រមព្រហ្មទណ្ឌ

[34] សៀវភៅទោសព្រហ្មទណ្ឌ លោកសាស្ត្រាចារ្យ កៅ សីហា ទំព័រ១១១

អាចប្រកាសទោសស្តីបន្ទោសនេះបានប្រសិនបើបានបំពេញលក្ខខណ្ឌចំនួនបីគឺ៖

១.ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើសត្រូវបានបញ្ចប់

២.ការខូចខាតត្រូវបានជួសជុលរួចហើយ

៣.ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ។

**១.ទោសធម្មតាចំពោះបទល្មើសឆបោក**

ក្រោយពីបានយល់នូវអ្វីដែលជាទោសច្បាស់ហើយ ជាបន្តទៀតយើងសូមធ្វើការបកស្រាយអំពីទោសដែលត្រូវអនុវត្តចំពោះបទល្មើសឆបោកដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌជាធរមានត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ក្នុងករណីដែលគ្មានស្ថានទម្ងន់ទោសណាមួយ។ ចំណែកច្បាប់ព្រហ្មទណ្ឌអន្តរកាលវិញបានផ្តន្ទាទោសចំពោះអំពើឆបោកដាក់ពន្ធនាគារពី១ឆ្នាំ ទៅ ៥ឆ្នាំ ដោយមិនមានកំណត់អំពីទោសពិន័យជាប្រាក់នោះឡើយ។

**២.ស្ថានទម្ងន់ទោស**

ការមិនរាងចាលគឺស្ថានទម្ងន់ទោសមួយដែលក្រមព្រហ្មទណ្ឌបានបញ្ញត្តិទុក។ នៅពេលដែលជនណាម្នាក់បានប្រព្រឹត្តបទល្មើសមួយហើយត្រូវបានផ្តន្ទាទោសជាស្ថាពរ ម្តងរួចហើយ តែក្រោយមកជនដដែលនេះបានទៅប្រព្រឹត្តបទល្មើសថ្មីណាមួយក្នុងអំឡុងពេលមិនទាន់ផុតកាលកំណត់នៃច្បាប់។[35] ជនដែលបានប្រព្រឹត្តបទល្មើសមិនរាងចាលនាំឱ្យមានការបន្ថែមទម្ងន់អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិម។ ហើយលក្ខខណ្ឌការកំណត់នៃការមិនរាងចាលច្បាប់ក៏បានកំណត់យ៉ាងច្បាស់លាស់ទើបចៅក្រមអាចយកទៅប្រកាសបាន។[36]

[35] មាត្រា៨៣ នៃក្រមព្រហ្មទណ្ឌ

[36] មាត្រា៨៤-៩២ នៃក្រមព្រហ្មទណ្ឌ

**ឧទាហរណ៍៖** បុរសម្នាក់បានប្រព្រឹត្តបទល្មើសលួចដែលចែងនៅមាត្រា៣៥៣ នៃក្រមព្រហ្មទណ្ឌ។ ហើយតុលាការបានផ្តន្ទាទោសគាត់ដាក់ពន្ធនាគារចំនួន២ឆ្នាំ។ បន្ទាប់ពីអនុវត្តទោសរួចមិនទាន់បាន៥ឆ្នាំផង ទើបតែបាន២ឆ្នាំ បុរសម្នាក់នោះក៏បានទៅប្រព្រឹត្តបទល្មើសថ្មីមួយទៀត ថាជាបទល្មើសឆបោកទៅចុះដែលមានចែងនៅមាត្រា៣៧៧នៃក្រមព្រហ្មទណ្ឌ។

ដូច្នេះបុរសម្នាក់នោះគាត់បានប្រព្រឹត្តបទល្មើសមជ្ឈិមមិនរាងចាល។ តែប្រសិនបើបន្ទាប់ពីបុរសម្នាក់នោះអនុវត្តទោសចប់ ហើយផុតរយៈពេល៥ឆ្នាំគាត់មិនដែលបានប្រព្រឹត្តបទល្មើសអ្វីសោះ ចំពោះបទមជ្ឈិម ឬបទឧក្រិដ្ឋណាមួយ ស្រាប់តែបាន៥ឆ្នាំ ១ខែក្រោយគាត់បានទៅប្រព្រឹត្តបទល្មើសមួយទៀត ក្នុងករណីនេះតុលាការមិនអាចចោទគាត់ថាប្រព្រឹត្តបទល្មើសនៅក្នុងស្ថានភាពមិនរាងចាលនោះទេ។

ក្រៅពីស្ថានទម្ងន់ទោសការមិនរាងចាលនៃការប្រព្រឹត្តបទល្មើសក៏នៅមានស្ថានទម្ងន់ទោសផ្សេងទៀតដែរ ដូចជាចរិតគ្រោះថ្នាក់នៃអំពើរបស់ជនល្មើស មានន័យថាការប្រព្រឹត្តអំពើល្មើសនោះគឺមានស្ថានភាពឃោរឃៅនិងព្រៃផ្សៃ ដែលធ្វើឱ្យប៉ះពាល់ និងមានគ្រោះថ្នាក់ដល់សង្គមធ្ងន់ធ្ងរជាដើម។

### ២.១ស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ

ក្រៅពីស្ថានទម្ងន់ទោសនៃការមិនរាងចាលការប្រព្រឹត្តបទល្មើសក៏នៅមានស្ថានទម្ងន់ទោសផ្សេងទៀត ដែលក្រមបានកំណត់ និងចែងច្បាស់លាស់។ ដូចជាក្រមមានការចាត់តាំង ការគាស់ទម្លុះទម្លាយ ការគិតទុកជាមុន ការផ្លោះរបង ការពួនស្ទាក់ និងការប្រើប្រាស់អាវុធ និងវត្ថុចាត់ទុកដូចអាវុធជាដើម។[37]

បន្ទាប់ពីបានយល់ពីលក្ខខណ្ឌមួយចំនួន នៃស្ថានទម្ងន់ទោសទូទៅខ្លះៗ ហើយ ឥឡូវយើងខ្ញុំ សូមលើកពីស្ថានទម្ងន់ទោសដែលបានកំណត់ ឬចែងនៅក្នុងបទល្មើសឆបោក ពីលក្ខខណ្ឌមួយចំនួនដែលជនល្មើសបានប្រព្រឹត្តហើយក្រមបានកំណត់បន្ថែមទម្ងន់ទោសទៅលើជនល្មើស។ ស្ថានភាពដែលពាក់ព័ន្ធទៅនឹងជនរងគ្រោះក៏ជា

[37] នៃក្រមមាត្រា៧៧-៨២ ព្រហ្មទណ្ឌ

ស្ថានទម្ងន់ទោសមួយដែរ ដែលតម្រូវឱ្យចៅក្រមបន្ថែមទម្ងន់ទោសទៅលើជនល្មើស ហើយស្ថានភាពទាំងនោះមានដូចជា៖

- បទល្មើសឆបោកបានប្រព្រឹត្តទៅលើ បុគ្គលដែលទន់ខ្សោយពិសេស ដោយសារមូលហេតុអាយុនៃបុគ្គលនោះ។

**ឧទាហរណ៍៖** បុរស **ក** បានទៅជនបទហើយអះអាងប្រាប់ទៅបុរសចំណាស់ម្នាក់ដែលមានអាយុប្រហែលជា៩០ឆ្នាំ ថាខ្លួនគេជាប្រធានក្រុមហ៊ុនមួយ ហើយត្រូវការដៃគូភាគហ៊ុនដើម្បីចូលរួមភាគហ៊ុនជាមួយគ្នាដើម្បីពង្រីកសាខាក្រុមហ៊ុននៅទីជនបទនោះ។ បន្ទាប់ពីបានស្តាប់ការអះអាង និងការពន្យល់ពីអត្ថប្រយោជន៍ដែលទទួលបានពីភាគហ៊ុននោះ បុរសវ័យចំណាស់ក៏បានចាប់អារម្មណ៍ និងជឿទុកចិត្ត ហើយបានយកលុយខ្លួនបានសន្សំទុកសម្រាប់ពេលចាស់ជរាទៅទិញភាគហ៊ុនក្រុមហ៊ុនដែលបុរស **ក** ប្រាប់នោះចំនួន៩០០០ ដុល្លារ តែធាតុពិតបុរស **ក** នោះមិនមែនជាប្រធានក្រុមហ៊ុនអ្វីទេ។

អំពើរបស់បុរស ក គឺជាអំពើឆបោកដែលមានស្ថានទម្ងន់ទោសបានប្រព្រឹត្តទៅលើបុគ្គលដែលទន់ខ្សោយពិសេសដោយសារមូលហេតុនៃអាយុរបស់បុគ្គលនោះ ដោយជនរងគ្រោះនៃអំពើឆបោកមានភាពចាស់ជរា។

- បទល្មើសឆបោកប្រព្រឹត្តទៅលើ ស្ត្រី មានគភ៌ កាលបើគភ៌ ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង។

**ឧទាហរណ៍៖** លោក A ជាមិត្តភក្តិជាមួយគ្នានឹងប្តីរបស់នារី B។ នៅថ្ងៃមួយលោក A បានចាញ់ល្បែងអស់លុយពីខ្លួនក៏បានប្រើល្បិចខលទៅនារី B ជាប្រពន្ធរបស់មិត្តខ្លួនដែលមានផ្ទៃពោះ ឬគភ៌ ៥ខែ។ ដោយប្រាប់ថាលោក **ក** ដែលជាប្តីរបស់នារី B បានជួបគ្រោះថ្នាក់ចរាចរណ៍។ បុកគេបណ្តាលឱ្យរងរបួសជាទម្ងន់ ហើយត្រូវ ជួសជុល សងការខូចខាត និងព្យាបាលរបួសឱ្យគេអស់ចំនួន១០០០ដុល្លារ។ នៅពេលនោះនារី B មានការភ័យយ៉ាងខ្លាំងដោយមិនបានគិតច្បាស់លាស់ក៏បានផ្ញើលុយទៅ ឱ្យលោក A ។ តែការពិតលោក **ក** ដែលជាប្តីរបស់នារី B នោះពុំមានគ្រោះថ្នាក់អ្វីទេ។

ដូច្នេះអំពើរបស់លោក A គឺជាបទល្មើសឆបោកដែលមានស្ថានទម្ងន់ទោសបានប្រព្រឹត្តទៅលើនារី B ដែលមានគភ៌ហើយខ្លួនបានដឹង និងមើលឃើញយ៉ាងច្បាស់ថានារី B ពិតជាមានផ្ទៃពោះពិតប្រាកដមែន។

- អំពើឆបោកប្រព្រឹត្តទៅលើបុគ្គលដែលទន់ខ្សោយពិសេស ដោយមូហេតុនៃជំងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនោះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង។

**ឧទាហរណ៍១**. លោក C បានអះអាងប្រាប់លោក ក ដែលជាជនពិការជើងម្ខាងដោយត្រូវគ្រាប់មីនកាលសម័យសង្គ្រាម ថាខ្លួនគាត់ជាប្រធានអង្គការមួយដែលអាចជួយជនពិការឱ្យមានការងារធ្វើ និងមានប្រាក់ខែសមល្មម។ លោក C តម្រូវឱ្យលោក ក ដែលជាជនពិការនោះត្រូវផ្តល់លុយឱ្យខ្លួនចំនួន៥០០ដុល្លារ នោះទើបខ្លួនអាចជួយឱ្យក្លាយជាសមាជិកអង្គការ និងរកការងារឱ្យធ្វើបាន។ ឮដូច្នេះលោក ក ដោយចង់រកការងារធ្វើផង ហើយមានការជឿជាក់លើការអះអាងក៏បានយល់ព្រមប្រគល់លុយឱ្យលោក C។ តែការពិតលោក C មិនមែនជាប្រធានអង្គការអ្វីនោះទេ។

អំពើរបស់លោក C គឺជាបទល្មើសឆបោកមានស្ថានទម្ងន់ទោសដែលបានប្រព្រឹត្តទៅលើជនពិការដោយខ្លួនបានដឹង និងមើលឃើញយ៉ាងច្បាស់ថាលោក ក បានពិការជើងម្ខាង។

**ឧទាហរណ៍២**. ស្ត្រី A បានទៅស្រុកមួយនៅឯជនបទដាច់ស្រយាល ដោយមានលក់ថ្នាំសង្កូវផង។ ហើយបានទៅដល់ភូមិមួយដែលមានមនុស្សចាស់មួយចំនួនឈឺដៃជើងជាដើម និងខ្លះទៀតមានជម្ងឺព្យាបាលមិនជាយូរមកហើយ។ នៅថ្ងៃមួយស្ត្រី A ក៏បានទៅលក់ថ្នាំនៅក្នុងភូមិនោះ ហើយបានទៅជួប លោក អ៊ំ ក ដែលគាត់មានជម្ងឺព្យាបាលមិនជាយូរឆ្នាំមកហើយ។ លោកអ៊ំ ក ក៏បាននិយាយពីអាការៈជម្ងឺរបស់គាត់ប្រាប់ទៅស្ត្រី A នោះ។ ហើយស្ត្រី A ក៏បានប្រាប់ពីរបៀបនៃការព្យាបាលជម្ងឺទៅលោកអ៊ំ ក ដោយចេះតែនិយាយពីនេះពីនោះទៅ ថាថ្នាំសង្កូវរបស់នាងអាចព្យាបាលជម្ងឺនេះបាន។ ហើយនាងក៏បាននិយាយថាប្រសិនបើលោកអ៊ំ ក ចង់ព្យាបាលជម្ងឺឱ្យជាសះស្បើយត្រូវតែទិញថ្នាំសង្កូវពី

នាងចំនួន២៥កញ្ចប់ ក្នុងតម្លៃមួយកញ្ចប់២ម៉ឺនរៀល ព្ធដូច្នោះដោយចង់ជាពីជម្ងឺផងលោកអ៊ំ ក ក៏បានទិញថ្នាំតាមការអះអាងរបស់ស្ត្រី A នោះតែធាតុពិតថ្នាំនោះមិនអាចព្យាបាលជម្ងឺលោកអ៊ំ ក នោះឱ្យជាសះស្បើយបានទេ។

អំពើរបស់ស្ត្រី A គឺជាអំពើឆបោកដែលមានស្ថានទម្ងន់ទោសដែលប្រព្រឹត្តទៅលើបុគ្គលទន់ខ្សោយពិសេសដោយមូលហេតុនៃជម្ងឺរបស់បុគ្គលនោះ។ ដូច្នេះទោសដែលស្ត្រី A ត្រូវអនុវត្តគឺមានទោសធ្ងន់ជាងទោសធម្មតា។

**២.២ស្ថានទម្ងន់ទោសផ្សេងទៀត**

បន្ទាប់ពីបានយល់នូវស្ថានទម្ងន់ទោសមួយចំនួនដែលទាក់ទងទៅនឹងជនរងគ្រោះដែលបានបញ្ញត្តិនៅក្នុងបទល្មើសឆបោកនេះ។ ឥឡូវយើងមកស្វែងយល់បន្ថែមនូវស្ថានទម្ងន់ទោស ផ្សេងៗទៀតដែលកំណត់នៅក្នុងលក្ខខណ្ឌនៃបទល្មើសឆបោកដែលតម្រូវឱ្យថៅក្រមធ្វើការប្រកាស ទោសទៅលើជនល្មើសដែលបានប្រព្រឹត្តបទល្មើសឆបោកដាក់ពន្ធនាគារពី២ (ពីរ) ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំកាលបើជនល្មើសជា៖

- ការបើបទល្មើសប្រព្រឹត្តដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។

**ឧទាហរណ៍**៖ លោក **ក** ជាមន្ត្រីនគរបាលនៃក្រសួងមហាផ្ទៃ។ នៅថ្ងៃមួយក្រសួងមហាផ្ទៃប្រកាសជ្រើសរើសមន្ត្រីនគរបាលជាច្រើននាក់ដោយការប្រឡងចូលតាមសមត្ថភាព។ លោក ក ដែលជាមន្ត្រីនគរបាលស្នងការខេត្តកំពង់ចាមក៏បានដើរបញ្ចុះបញ្ចូលប្រជាប្រជាពលរដ្ឋជាច្រើននាក់នៅខេត្តកំពង់ចាមនោះថា បើចង់ចូលធ្វើជាមន្ត្រីនគរបាលនៅក្រសួងមហាផ្ទៃត្រូវឱ្យថវិកាមកខ្លួនចំនួន៩០០០ដុល្លារដើម្បីរត់ការចូលធ្វើជានគរបាលនៃក្រសួងមហាផ្ទៃដោយមិនបាច់ប្រឡង។ ប្រជាពលរដ្ឋដោយសារតែចង់ធ្វើជាមន្ត្រីនគរបាលក៏ព្រមប្រគល់លុយទៅតាមដែលលោក ក ទាមទារ។ ក្រោយពីបានលុយនោះហើយ លោក ក មិនបានរត់ការឱ្យប្រជាពលរដ្ឋទាំងនោះបានចូលធ្វើមន្ត្រីនគរបាលស្អីនោះទេគឺយកលុយនោះទៅស៊ីចាយយ៉ាងសប្បាយអស់ទៅ។

- កាលបើបទល្មើសប្រព្រឹត្តដោយបុគ្គលដែលតាំងខ្លួនជាអ្នករាជការសាធារណៈ។

**ឧទាហរណ៍៖** បុរសម្នាក់ឈ្មោះ ឈ បានអះអាងប្រាប់ប្រជាពលរដ្ឋនៅខេត្តកំពតដែលកំពុងមានជម្លោះរឿងដីធ្លីជាមួយក្រុមហ៊ុនដាំអំពៅមួយថាខ្លួនជាមន្ត្រីនៃក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចុះមកដោះស្រាយជម្លោះជូនប្រជាពលរដ្ឋ ហើយគាត់ក៏បាននិយាយទៀតថាបើបងប្អូនដែលកំពុងមានជម្លោះចង់ដោះស្រាយឱ្យបានឆាប់រហ័យត្រូវឱ្យលុយមកខ្លួនមួយចំនួនដើម្បីរត់ការដោះស្រាយ។ ប្រជាលរដ្ឋឮដូច្នេះក៏ព្រមប្រគល់លុយទៅឱ្យលោក ឈ នោះទៅ ក្រោយពីបានទទួលលុយពីប្រជាពលរដ្ឋហើយ លោក ឈ ក៏គេចខ្លួនបាត់ទៅព្រោះគេមិនមែនជាមន្ត្រីនៃក្រសួងដែនដី នគរូបនីយកម្ម និងសំណង់នោះទេ។

- កាលបើបទល្មើសប្រព្រឹត្តដោយបុគ្គលដែលធ្វើការអំពាវនាវដល់សាធារណៈជនដើម្បី បោះពុម្ពចេញឱ្យប្រើប្រាស់នូវមូលបត្រ[38]។

**ឧទាហរណ៍៖** លោក **ឆ** បានអះអាងប្រាប់សាធារណៈជនថាខ្លួនមានក្រុមហ៊ុនមួយ ហើយបានប្រកាសលក់ភាគហ៊ុនក្រុមហ៊ុននោះទៅឱ្យប្រជាពលរដ្ឋ។ បន្ទាប់ពីការប្រកាសលក់ភាគហ៊ុននោះប្រជាពលរដ្ឋបាននាំគ្នាទៅទិញភាគហ៊ុនក្រុមហ៊ុននោះយ៉ាងច្រើនពីលោក **ឆ** ដោយមួយហ៊ុនតម្លៃ១០០០ដុល្លារ។ បន្ទាប់ពីបោះពុម្ពមូលបត្រលក់ភាគហ៊ុនបានច្រើនហើយលោក **ឆ** ក៏បានរត់គេចខ្លួនបាត់ទៅ ព្រោះក្រុមហ៊ុនលោក **ឆ** ប្រកាសលក់ភាគហ៊ុននោះគឺមានតែឈ្មោះគឺគ្មានក្រុមហ៊ុនពិតប្រាកដអ្វីទេ។

- កាលបើបទល្មើសប្រព្រឹត្តដោយបុគ្គលដែលធ្វើការអំពាវនាវដល់សាធារណៈជន ដើម្បីអង្គាសមូលនិធិសម្រាប់ជំនួយមនុស្សធម៌ និងសង្គមកិច្ច។

**ឧទាហរណ៍៖** លោក Z បានធ្វើការអំពាវនាវដល់ប្រជាពលរដ្ឋកម្ពុជាឱ្យជួយឧបត្ថម្ភដល់អង្គការមនុស្សធម៌មួយដើម្បីជួយដល់កុមារកំព្រា និងជនពិការដែលអង្គការយកមកចិញ្ចឹម និងអប់រំ បន្ទាប់ពីធ្វើការអំពាវនាវនោះប្រជាពលរដ្ឋបានឧបត្ថម្ភលុយ និងសម្ភារជាច្រើនទៅឱ្យលោក Z ។ ក្រោយពីបានលុយ និងសម្ភារយ៉ាងច្រើននោះលោក Z មិនយកទៅជួយដល់អង្គការដែលគេបានអះអាងនោះទេគឺយកទៅចាយវាយដោយខ្លួនឯងអស់ទៅហើយអង្គការមនុស្សធម៌នោះក៏មិនមានដែរ។

- កាលបើបទល្មើសប្រព្រឹត្តដោយបុគ្គលដែលមានក្រុមការចាត់តាំង។[39]

[38] មូលបត្រ គឺជាប័ណ្ណដែលតំណាងឱ្យសិទ្ធិលើកម្មសិទ្ធិរបស់ម្ចាស់ប័ណ្ណនោះទៅលើក្រុមហ៊ុន

**ឧទាហរណ៍៖** លោក **ក ខ និង ស្ត្រី ឆ** បានរៀបចំគំរោងមួយឆបោកទៅលើជនណាម្នាក់តាមប្រព័ន្ធទូរស័ព្ទ។ បន្ទាប់ពីរៀបចំគម្រោងរួច **ក** បានខលទៅលេខមួយតាមការស្មានឬព្រាវ ចំលេខលោក **ត** ហើយក៏ប្រាប់លោក **ត** ថាត្រូវរង្វាន់ចំនួន១០០០០ដុល្លារ ហើយលោក **ក** ក៏តម្រូវឱ្យលោក **ត** ខលទៅស្ត្រី **ឆ** ដើម្បីស្តាប់ការណែនាំអំពីលក្ខខណ្ឌដើម្បីអាចបើករង្វាន់បាន។ ក្រោយពីលោក **ក** បិទទូរស័ព្ទទៅលោក **ត** ក៏បានខលទៅស្ត្រី **ឆ** ដែលលោក **ក** បានអះអាងប្រាប់នោះ ហើយស្ត្រី **ឆ** បានណែនាំតាមគម្រោងដែលពួករៀបចំទុកដោយតម្រូវឱ្យលោក **ត** មានអត្តសញ្ញាណប័ណ្ណ និងប្រគល់លុយចំនួន១០០០ដុល្លារឱ្យទៅលោក **ខ** ជាមុនសិនទើបអាចបើករង្វាន់នោះបាន។ លោក **ត** ក៏បានប្រគល់លុយទៅលោក **ខ** តាមការណែនាំរបស់ស្ត្រី **ឆ** នោះទៅ ក្រោយពីទទួលលុយរួចហើយពួកគេទាំងបីនាក់ក៏បានរត់គេចខ្លួនបាត់។

**៣.ការប៉ុនប៉ងមានទោស**

ការប្រព្រឹត្តបទល្មើសណាមួយដែលមិនបានសម្រេចដោយប្រការណាមួយដែលមិនមែនកើតចេញពីឆន្ទៈរបស់ជនល្មើស តែអំពើរបស់ជនល្មើសត្រូវបានរារាំង ឬអាក់ខានដោយកាលៈទេសៈខាងក្រៅណាមួយដែលនាំឱ្យការប្រព្រឹត្តនោះមិនបានសម្រេច។ ការប្រព្រឹត្តបទល្មើសមិនបានសម្រេចនេះហើយដែលច្បាប់បានចាត់ទុកថាជាការប៉ុនប៉ង ហើយត្រូវផ្តន្ទាទោសដូចគ្នានឹងបទល្មើសបានសម្រេចដែរ។ ហើយដើម្បីអាចផ្តន្ទាទោសការប៉ុនប៉ងនេះបានលុះត្រាតែបានបំពេញនូវលក្ខខណ្ឌចំនួនពីរ៖

- ចារីបានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស។
- ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬអាក់ខាន ដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន។

គ្រប់បទឧក្រិដ្ឋទាំងអស់សុទ្ធតែមានអំពើប៉ុនប៉ង តែចំពោះបទល្មើសមជ្ឈិមវិញការប៉ុនប៉ងទាមទារឱ្យមានច្បាប់ចែងទុកជាមុនយ៉ាងច្បាស់លាស់ នោះទើបថៅក្រមអាច

[39] មាត្រា៣៨០ នៃក្រមព្រហ្មទណ្ឌ

ប្រកាស ផ្តន្ទាទោសបាន។ តួយ៉ាងដូចបទល្មើសឆបោកនេះអ៊ីចឹងដែលក្រមព្រហ្មទណ្ឌ មាត្រា៣៨១បានកំណត់អំពីការប៉ុនប៉ងមានទោសដូចគ្នានឹងបទល្មើសឆបោកបានសម្រេចនេះដែរ។[40]

**ឧទាហរណ៍:** លោក ក បានអះអាងថាគាត់ជាមេធាវីនៅក្រុមហ៊ុនមេធាវីមួយនៅភ្នំពេញ ប្រាប់ទៅប្រជាពលរដ្ឋមួយនៅខេត្តកំពត ដែលមានបញ្ហាជំលោះរឿងក្តីនៅតុលាការ។ ហើយប្រាប់ប្រជាពលរដ្ឋនោះថាបើចង់ដោះស្រាយរឿងក្តីឱ្យបានលឿនត្រូវប្រគល់លុយឱ្យគាត់ (លោក ក) ចំនួន៣០០០ដុល្លារដើម្បីរត់ការ។ ប្រជាពលរដ្ឋរៀបនឹងប្រគល់លុយជូនលោក ក ស្រាប់តែតំណាងក្រុមហ៊ុនមេធាវីដែលលោក ក អះអាងថាខ្លួនជាសមាជិកនោះមកដល់ ហើយបានប្រាប់ទៅប្រជាពលរដ្ឋនោះថាលោក ក មិនមែនជាសមាជិកនៃក្រុមហ៊ុនមេធាវីរបស់ខ្លួនទេ ហើយលោក ក ក៏មិនមែនជាមេធាវីដែរ។ ដូច្នេះអំពើរបស់លោក ក គឺជាអំពើឆបោក តែមិនបានសម្រេចនោះទេ ដោយត្រូវបានអាក់ខាន ឬរាំងស្ទះដោយកាលៈទេសៈខាងក្រៅ។

**៤.ទោសបន្ថែម**

ទោសបន្ថែមគឺទោសបន្ទាប់បន្សំដែលតុលាការយកទៅប្រកាសបន្ថែមពីលើមូលទោសដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។ ហើយទោសបន្ថែមនេះតុលាការអាចយកទៅប្រកាសបានលុះត្រាតែមានច្បាប់ចែងកំណត់យ៉ាងច្បាស់ នោះទើបថៅក្រមអាចយកទៅប្រកាសបានចំពោះបទឧក្រិដ្ឋ មជ្ឈិម ឬបទលហុដែលត្រូវចោទប្រកាន់។ ហើយក្នុងករណីដែលច្បាប់បានកំណត់ទុកមុនថាតុលាការត្រូវតែប្រកាសទោសបន្ថែមជាកាតព្វកិច្ច នោះតុលាការត្រូវតែប្រកាសជាដាច់ខាត។ ប្រសិនបើច្បាប់មិនបានកំណត់ជាកាតព្វកិច្ចនោះទេតុលាការអាចប្រកាសទោសបន្ថែមក៏បាន មិនប្រកាសក៏បាន ទោះបីជាច្បាប់ចែងអំពីទោសបន្ថែមចំពោះបទល្មើសនោះក៏ដោយ ច្បាប់ទុកឱ្យថៅក្រមជាអ្នកមានឆន្ទានុសិទ្ធិសម្រាប់ប្រកាសទោសបន្ថែមនេះ។[41]

[40] មាត្រា២៧ នៃក្រមព្រហ្មទណ្ឌ

[41] មាត្រា៥៤ នៃក្រមព្រហ្មទណ្ឌ

ទោសបន្ថែមសម្រាប់បទល្មើសឆបោកនេះ គឺមានជាច្រើនចំណុចដែលបាន កំណត់ឱ្យចៅក្រមអាចជ្រើសរើសយកទោសណាមួយក្នុងចំណោមទោសបន្ថែមទាំង១៣ នោះ មកប្រកាសចំពោះជនល្មើសឱ្យត្រូវទៅតាមស្ថានភាពដែលបានប្រព្រឹត្តល្មើស។[42]

**កថាខណ្ឌទី៥.បទល្មើសប្រហាក់ប្រហែលនឹងបទល្មើសឆបោក**

**១.ការបន្លំ**

ការបោកបន្លំគឺអំពើរបស់ជនមួយដែលដឹងថាខ្លួនគ្មានលទ្ធភាពដាច់ខាតនឹងបង់ថ្លៃ ឬដែលសម្រេចចិត្តមិនបង់ថ្លៃ

- ឱ្យគេបម្រើម្ហូបអាហារ ឬភេសជ្ជៈនៅក្នុងរង្គសាល ភោជនីយដ្ឋាន ឬនៅក្នុងគ្រឹះស្ថានដទៃទៀតដែលបើកចំហដល់សាធាណៈជន។
- ឱ្យគេប្រគល់បន្ទប់មួយ និងកាន់កាប់បន្ទប់នេះនៅក្នុងសណ្ឋាគារ ឬគ្រឹះស្ថានដទៃទៀតដែលបើកចំហដល់សាធារណៈជន។
- ឱ្យគេដឹកជញ្ជូនខ្លួនតាមត្រីចក្រយាន តាមរថយន្តឈ្នួល ឬតាមមធ្យោបាយដឹកជញ្ជូនផ្សេងទៀត។[43]

**ឧទាហរណ៍៖**

១. លោក ក បានចូលទៅក្នុងភោជនីយដ្ឋានមួយកន្លែងហើយបានឱ្យគេបម្រើសេវាស្រាបៀរ និងម្ហូបអាហារ តែដល់ពេលគិតលុយបុរសនោះបែរជាឆ្លើយថាគ្មានលុយបង់ថ្លៃសេវាទាំងនោះ។

២.បុរសម្នាក់បានទៅជួលផ្ទះសំណាក់ស្នាក់នៅមួយយប់ដល់ពេលគិតលុយស្រាប់តែបុរសនោះពុំព្រមបង់ថ្លៃសេវា។

៣.បុរសម្នាក់គាត់ពុំមានលុយសូម្បីមួយរយរៀល ហើយគាត់បានឡើងជិះលើរថយន្តឈ្នួលឱ្យគេដឹកគាត់ទៅស្រុកកំណើត ដល់ពេលដល់កន្លែងត្រូវឈប់គាត់បែរជាឆ្លើយថាពុំមានប្រាក់បង់ថ្លៃឈ្នួលរថយន្តទៅវិញ។

**២.ការរំលោភលើភាពល្ងង់ខ្លៅ និងបុគ្គលទន់ខ្សោយ**

[42] មាត្រា៣៨២ នៃក្រមព្រហ្មទណ្ឌ

[43] មាត្រា៣៨៤ នៃក្រមព្រហ្មទណ្ឌ

ការទាញយកផលប្រយោជន៍ដោយចេតនាដោយរំលោភលើភាពល្ងង់ខ្លៅ ឬ ភាពទន់ខ្សោយនៃបុគ្គលដែលបណ្តាលមកពីអាយុ ស្ថានភាពមានគភ៌ ជំងឺ ឬពិការភាព ដោយបង្ខំដោយបុគ្គលនេះ ឱ្យប្រព្រឹត្តអំពើ ឬមិនប្រព្រឹត្តអំពើដែលធ្វើឱ្យខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងររបស់បុគ្គលនេះ។[44]

**ឧទាហរណ៍៖** លោក ក បានបញ្ចុះបញ្ចូលឱ្យលោក ខ លក់ដីឱ្យខ្លួនក្នុងតម្លៃមួយដែលថោកជាងទីផ្សារដីធ្លីដោយលោក ក បានអះអាងថាខ្លួនបានឱ្យតម្លៃនេះថ្លៃជាងតម្លៃទីផ្សារដីធ្លីទៅទៀត។ ដោយសារតែមិនបានដឹងពីតម្លៃដីធ្លី និងត្រូវការលុយដើម្បីយកទៅព្យាបាលជម្ងឺផងនោះលោក ខ ក៏ព្រមលក់ដីនេះឱ្យទៅលោក ក ក្នុងតម្លៃនោះទៅ។ តាមពិតតម្លៃដីរបស់លោក ខ គឺមានតម្លៃថ្លៃជាងតម្លៃដែលលក់នេះរហូតទៅ១០ដងឯណោះ។

## ផ្នែកទី២.បទរំលោភលើទំនុកចិត្ត

### កថាខណ្ឌទី១.និយមន័យបទល្មើសរំលោភលើទំនុកចិត្ត

#### ក.ច្បាប់ព្រហ្មទណ្ឌអន្តរកាល

ច្បាប់ព្រហ្មទណ្ឌអន្តរកាលបានឱ្យនិយមន័យថា ជនណាដែលគៃបន្លំ ឬ បំបាត់ឱ្យខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬ អ្នកកាន់កាប់ទ្រព្យសម្បត្តិ ប្រាក់កាស ទំនិញ ឬ គ្រប់ឯកសារដែលមាន ឬ ដែលចែងអំពីកាតព្វកិច្ច ឬ ការដោះបន្ទុក ដែលគេប្រគល់មកឱ្យខ្លួនក្នុងលក្ខណៈនៃការជួល ជាការដាក់ដំកល់ទុក ជាអាណត្តិ ជាការឱ្យខ្ចីប្រើ ឬ ដើម្បីការងារមានបៀវត្ស ឬ គ្មានបៀវត្ស ដែលត្រូវប្រគល់ឱ្យគេវិញ ឬ ធ្វើជាតំណាង ឬ សម្រាប់ប្រើប្រាស់ ឬ ជាមុខការមានកំណត់។[45]

#### ខ.ក្រមព្រហ្មទណ្ឌបច្ចុប្បន្ន

អំពើរំលោភលើទំនុកចិត្ត គឺជាអំពើគៃបំបាត់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ នាំឱ្យខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលគេបានប្រគល់ឱ្យ

[44] មាត្រា៣៨៣ នៃក្រមព្រហ្មទណ្ឌ

[45] មាត្រា៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល

បុគ្គលនោះ ហើយបុគ្គលនោះ បានយល់ព្រម ដោយមានភារកិច្ចប្រគល់សងវិញ បង្ហាញ ឬ យកមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់។[46]

**កថាខណ្ឌទី២.ធាតុផ្សំនៃបទល្មើសរំលោភលើទំនុកចិត្ត**

**១.ធាតុនីត្យានុកូលនៃបទរំលោភលើទំនុកចិត្ត**

ធាតុនីត្យានុកូល ឬធាតុច្បាប់ត្រូវមានកំណត់ចែងឱ្យបានច្បាស់លាស់អំពីអំពើណាមួយដែលត្រូវបានកំណត់ថាជា បទល្មើសព្រហ្មទណ្ឌ ដែលត្រូវផ្តន្ទាទោសទើបអាចធ្វើការចោទប្រកាន់បាន។ ជាក់ស្តែង អំពើរំលោភលើទំនុកចិត្ត មានចែងនៅក្នុងក្រមព្រហ្មទណ្ឌត្រង់មាត្រា៣៩១,៣៩២,និងមាត្រា៣៩៦។ រីឯនៅក្នុងច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាលចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ១៩៩២ ដែលមានចែងនៅត្រង់មាត្រា ៤៦ ថាជាការរំលោភលើសេចក្តីទុកចិត្ត រីឯក្រមព្រហ្មទណ្ឌថ្មីគឺ ជាការរំលោភលើទំនុកចិត្ត។[47] នៅក្នុងធាតុនីត្យានុកូលនេះប្រសិនបើអំពើរំលោភលើទំនុកចិត្ត ត្រូវបានជនល្មើសប្រព្រឹត្តមុនក្រមថ្មីចូលជាធរមាន នោះការផ្តន្ទាទោសតុលាការត្រូវអនុវត្តតាមក្រមព្រហ្មទណ្ឌអន្តរកាលមាត្រា៤៦។ តែប្រសិនបើអំពើល្មើសនេះ ត្រូវបានប្រព្រឹត្តក្រោយការប្រកាសចូលជាធរមាននូវក្រមព្រហ្មទណ្ឌថ្មីឆ្នាំ ២០០៩ តុលាការត្រូវអនុវត្តទោសតាមមាត្រា ៣៩១។

**២.ធាតុសត្យានុម័តនៃបទរំលោភលើទំនុកចិត្ត**

ធាតុសត្យានុម័តនៃបទល្មើស គឺជាផ្នែកខាងក្រៅនៃបទល្មើស ឬជាអ្វីដែលបទល្មើស ស្តែងចេញឱ្យឃើញរួមមាន[48]៖

- អំពើបង្កគ្រោះថ្នាក់ដល់សង្គម
- បច្ច័យ
- ទំនាក់ទំនងហេតុផលរវាងអំពើ និង បច្ច័យ
- ពេលវេលា ទីកន្លែង ឧបាយកល ឧបករណ៍ ( មធ្យោបាយ) ទិដ្ឋភាពនានាជុំវិញបទល្មើស។

**២.១ការព្រមព្រៀងប្រគល់វត្ថុរវាងជនរងគ្រោះ និងជនល្មើស**

[46] មាត្រា៣៩១ នៃក្រមព្រហ្មទណ្ឌ

[47] សៀវភៅនីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ កៅ សីហា ទំព័រ៨០

[48] សៀវភៅនីតិព្រហ្មទណ្ឌទូទៅខ្មែរ សាស្ត្រាចារ្យ កៅ សីហា ទំព័រ៣២

ធាតុផ្សំសម្ភារនៅក្នុងន័យនេះសំដៅទៅលើ ទ្រព្យ ប្រាក់កាស ទំនិញ ឬឯកសារណាមួយ ដែលមាន ឬ ដែលចែងពីកាព្វកិច្ច ឬ ការដោះបន្ទុកដែលគេបានប្រគល់មកឱ្យ ខ្លួនក្នុងលក្ខណៈនៃការជួល ជាការដាក់ដំកល់ទុក ជាអាណត្តិ ជាការឱ្យខ្ចីប្រើ ឬ ជាប្រាក់កម្រៃ សម្រាប់ការងារមាន ឬ គ្មានបៀវត្ស...។ ភាសានេះស្មុគស្មាញ ប៉ុន្តែនៅក្នុងរឿងជាច្រើន ទ្រព្យ ប្រាក់កាស ទំនិញ ឬ ឯកសារ ណាមួយដែលមាន ឬ ដែលចែងអំពីកាព្វកិច្ច ឬ ការដោះបន្ទុកអាចនិយាយឡើងវិញយ៉ាងសាមញ្ញថាជាទ្រព្យ។ ផ្នែកបន្ទាប់នៃឃ្លានេះបញ្ជាក់ថា ទ្រព្យទាំងនោះត្រូវតែបានគេទុកចិត្តប្រគល់ឱ្យជនជាប់ចោទ ជាការជួល ជាការដាក់ដំកល់ទុក ជាអាណត្តិ ជាការឱ្យខ្ចីប្រើ ឬ ជាប្រាក់កម្រៃសម្រាប់ការងារមាន ឬ គ្មានប្រាក់បៀវត្ស...។ វាបានពិពណ៌នា**កិច្ចសន្យាខុសគ្នាចំនួនប្រាំមួយប្រភេទ**ដែលគេឱ្យជនដទៃទទួលខុសត្រូវ ក្នុងការអនុវត្តជាក់ស្តែង ការប្រគល់ទ្រព្យឱ្យអ្នកដទៃ ទំនងជា និងនិយាយដល់ទម្រង់ណាមួយនៃកិច្ចសន្យាទាំងប្រាំមួយបែប (កិច្ចសន្យាជួល កិច្ចសន្យាផ្ញើទុក កិច្ចសន្យាបញ្ចាំ កិច្ចសន្យាឱ្យខ្ចីប្រើ កិច្ចសន្យាអាណត្តិ កិច្ចសន្យាការងាររវាងកម្មករ និងនិយោជិត ឬ មិនមែនរវាងនិយោជក និងកម្មករនិយោជិត) តាមរយៈការកាត់យល់ ឬ មួយដោយជាក់លាក់។[49] ក្នុងករណីភាគច្រើនបញ្ហាសំខាន់គឺ តើគេបានប្រគល់ទ្រព្យឱ្យទៅជនជាប់ចោទ ឬ អត់? មិនមែនប្រភេទកិច្ចសន្យាដែលគេបានបង្កើតឡើង រវាងជនជាប់ចោទ និង ម្ចាស់ទ្រព្យឡើយ។ ហេតុដូច្នេះហើយ ការនិយាយអំពីធាតុផ្សំ នៃបទល្មើសនេះ ក្នុងករណីភាគច្រើន គេអាចនឹងនិយាយឡើងវិញថា ទ្រព្យត្រូវបានគេទុកចិត្តប្រគល់ឱ្យជនជាប់ចោទទទួលខុសត្រូវ។

ចំណែកឯកក្រមព្រហ្មទណ្ឌបច្ចុប្បន្នវិញគឺ ពុំបានរៀបរាប់អំពីកិច្ចសន្យាប្រភេទណាមួយច្បាស់លាស់ទេ ប៉ុន្តែបានប្រើពាក្យថា យល់ព្រម ដែលបង្ហាញឱ្យឃើញពីកិច្ចសន្យាដែលបានកើតឡើងរវាងជនល្មើស និងជនរងគ្រោះ ហើយកិច្ចសន្យានោះបានដាក់បន្ទុកជាភារកិច្ចដល់ជនល្មើសក្នុងការសងមកវិញ បង្ហាញ ឬយកមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះទៅធ្វើការប្រើប្រាស់ជាកំណត់។ នៅក្នុងន័យនេះ ក្រមព្រហ្មទណ្ឌគឺពុំបាន

[49] សេចក្តីប្រកាសរួមនាំលេខ ០២ របស់ក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូលស្តីពីការអនុវត្តមាត្រា ៤៦នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល (ការរំលោភលើទំនុកចិត្ត)។

កម្រិតធាតុផ្សំនៃបទល្មើសរំលោភលើទំនុកចិត្តទេ តែសំដៅទៅលើរាល់កិច្ចសន្យាដែលបង្កើតកាតព្វកិច្ចណាមួយជាក់លាក់ ទោះបីជាកិច្ចសន្យានោះមានឈ្មោះអ្វីក៏ដោយ។ កិច្ចសន្យាដែលជាមូលដ្ឋាននាំឱ្យមានបទល្មើសនោះ រួមមាន៖ ភតិសន្យា (ជួល) អាណត្តិ ការងារ ខ្ចីប្រើ បញ្ញើ។ល។

**២.២ជនល្មើសពុំបានបំពេញភាតព្វកិច្ចប្រគល់សងឬប្រើប្រាស់តាមការកំណត់**

ធាតុផ្សំនេះបង្កប់នៅក្នុងភាសាថា ដោយបានសន្យាថាសងវិញ ឬ ប្រគល់ឱ្យវិញ ឬ ប្រើប្រាស់តាមការព្រមព្រៀងគ្នាណាមួយ...។ ច្បាស់ណាស់ថា ធាតុផ្សំនេះអាស្រ័យនិងអត្ថិភាពនៃធាតុផ្សំទីមួយ។ ជនជាប់ចោទត្រូវតែបានគេទុកចិត្តប្រគល់ទ្រព្យឱ្យទទួលខុសត្រូវ មុននឹងគេអាចសន្យាថាសងវិញ ឬ ប្រគល់ឱ្យវិញ ឬ ប្រើប្រាស់តាមការព្រមព្រៀងណាមួយ។ **ភាសានេះពិពណ៌នាអំពីទង្វើបីយ៉ាង** ដែលជនជាប់ចោទត្រូវតែបានសន្យាថានឹងធ្វើចំពោះទ្រព្យនោះ។ **ទីមួយជនជាប់ចោទអាចសន្យាថានឹងសងទ្រព្យនោះវិញ**។ ករណីនេះពិពណ៌នាស្ថានភាពដែលជនជាប់ចោទបានខ្ចីរបស់អ្វីមួយដូចជារថយន្ត ហើយបានសន្យាថានឹងប្រគល់របស់នោះសងទៅម្ចាស់វិញ។ ជនជាប់ចោទកាន់កាប់ទ្រព្យដោយស្របច្បាប់ ព្រោះម្ចាស់ទ្រព្យបានប្រគល់វាទៅឱ្យរូបគេដោយស្ម័គ្រចិត្ត ប៉ុន្តែគេបានសន្យាចំពោះម្ចាស់របស់នោះថានឹងប្រគល់សងវិញ។ ប្រការនេះបានកំហិតសិទ្ធិរបស់គេលើទ្រព្យនោះ។ គេមិនអាចលក់វា ឬ ប្រគល់វាជាបន្តឱ្យទៅនរណាទៀតបានទេ។ គេត្រូវតែប្រគល់ទ្រព្យនោះសងម្ចាស់វិញ។[50]

**ឧទាហរណ៍៖** ជនជាប់ចោទអាចជួលគ្រឿងចក្រកសិកម្មមួយគ្រឿង សម្រាប់រយៈពេលបីឆ្នាំ។ ម្ចាស់ទ្រព្យ និងជនជាប់ចោទបានព្រមព្រៀងគ្នាថា ម្ចាស់ទ្រព្យមានសិទ្ធិទិញគ្រឿងចក្រនោះវិញ ក្នុងតម្លៃមួយដែលបានព្រមព្រៀងគ្នានៅពេលចប់រយៈពេលកំណត់បីឆ្នាំនោះ។ បើសិនជាម្ចាស់ទ្រព្យ មិនចង់ទិញយកគ្រឿងចក្រនោះវិញទេ ទើបជនជាប់ចោទមានសិទ្ធិលក់ ទៅឱ្យអ្នកដែលហ៊ានថ្លៃខ្ពស់ជាងគេ។ នៅក្នុងបណ្ដាប្រទេសដែលគេគោរពតាមប្រព័ន្ធច្បាប់អង់គ្លេស គេអាចពិពណ៌នាករណីនេះ ថាជាការអាចយកបានទ្រព្យដែលជាកម្មវត្ថុនៃសិទ្ធិ មានឱកាសទិញមុនគេ។ ចំណុចសំខាន់នោះគឺ ជនជាប់ចោទបានសន្យា

[50] ការភាក្សាលើវិស័យឯកជន លេខ២៣ រឿងក្ដីរំលោភលើទំនុកចិត្ត

ចំពោះម្ចាស់ទ្រព្យថា គេកំហិតសិទ្ធិរបស់គេក្នុងការចាត់ចែងលើទ្រព្យនោះ។ គេមិនអាចលក់ទ្រព្យនោះបានតាមចិត្ត ដោយមិនបានស្នើផ្តល់វាទៅឱ្យម្ចាស់របស់វិញមុនគេនោះទេ។

**បែបផែនទីពីរ ដែលធាតុផ្សំនេះត្រូវបំពេញគឺ តាមរយៈការសន្យាថានឹងប្រើប្រាស់ទ្រព្យនោះតាមការព្រមព្រៀងគ្នា។** ជាថ្មីម្តងទៀត ចំណុចសំខាន់នៅទីនេះគឺ ជនជាប់ចោទបានសន្យាចំពោះម្ចាស់របស់ថា ទប់ស្កាត់ខ្លួនឯងមិនឱ្យចាត់ទុកទ្រព្យនោះ ដូចជារបស់ផ្ទាល់ខ្លួនទេ។ ករណីជាគំរូគឺករណីនិយោជិតម្នាក់ ដែលត្រូវ បាននិយោជកទុកចិត្តប្រគល់ប្រាក់ ឱ្យកាន់សម្រាប់បំពេញគោលដៅកំណត់មួយ។

**ឧទាហរណ៍៖** និយោជិតនោះត្រូវបាននិយោជក ប្រគល់ប្រាក់ឱ្យយកទៅដាក់ផ្ញើនៅធនាគារ ពោលគឺបានទទួលទ្រព្យសម្រាប់ប្រើប្រាស់តាមការកំណត់មួយ។ គេកាន់កាប់វាស្របច្បាប់ ប៉ុន្តែគេកាន់កាប់វាសម្រាប់តែគោលដៅមួយដែលបានកំណត់តែប៉ុណ្ណោះ គឺយកប្រាក់នោះទៅធនាគារ ហើយដាក់ផ្ញើវានៅទីនោះ។ គេបានធ្វើការសន្យាយ៉ាងជាក់លាក់ ឬ តាមការកាត់យល់ហើយប្រការនោះបានកំហិតលទ្ធភាពរបស់គេ មិនឱ្យចាត់ទុកប្រាក់នោះ ថាជារបស់ផ្ទាល់ខ្លួនទេ។

**ចំណុចសំខាន់សម្រាប់ផ្នែកទាំងបីនៃធាតុផ្សំនេះគឺ ជនជាប់ចោទបានសន្យាចំពោះម្ចាស់ទ្រព្យ ដែលដាក់កំហិតដល់សិទ្ធិរបស់គេ ក្នុងការចាត់ចែងការលើទ្រព្យនោះ។ ការរំលោភដោយចេតនាលើការសន្យានេះ គឺជាការរំលោភលើសេចក្តីទុកចិត្ត។**

### ២.៣ជនជាប់ចោទបានបំបាត់ ឬ គៃបន្លំទ្រព្យរបស់ជនរងគ្រោះ

ធាតុផ្សំកើតឡើង នៅពេលដែលជនជាប់ចោទធ្វេសប្រហែស មិនបានធ្វើតាមការសន្យាទាក់ទងនឹងទ្រព្យ។ វាកើតចេញពីភាសាថា ជនណាដែលគៃបន្លំ ឬ បំបាត់ ទ្រព្យធ្វើឱ្យខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬ អ្នកកាន់កាប់ទ្រព្យ។[51] ប្រការនេះទាក់ទង និងការធ្វេសប្រហែស គោរពមិនបានតាមការសន្យាក្នុងធាតុផ្សំទីពីរ។ បើសិនជាជន

[51] ពាក្យថា ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬ អ្នកកាន់កាប់ ត្រូវគេប្រើនៅក្នុងច្បាប់នេះជាជំនួសឱ្យពាក្យថា ម្ចាស់ទ្រព្យ ដែលងាយស្រួលប្រើជាងនេះដើម្បីបញ្ជាក់ឱ្យច្បាស់ថាការរំលោភលើសេចក្តីទុកចិត្តអាចប្រព្រឹត្តលើជនណាម្នាក់ ដែលជាអ្នកកាន់កាប់ទ្រព្យនោះដោយស្របច្បាប់ ទោះបីជាអ្នកនោះមិនមែនជាម្ចាស់ពិតប្រាកដក៏ដោយ។ ក្នុងករណីជាច្រើនភាពខុសគ្នានេះ មិនមានន័យអ្វីទេ ពីព្រោះអ្នកដែរប្រគល់ទ្រព្យឱ្យជនជាប់ចោទទទួលខុសត្រូវគឺជាម្ចាស់ពិតប្រាដក។

ជាប់ចោទបានសន្យាសងទ្រព្យវិញ នោះគេត្រូវតែខំប្រឹងសងវាវិញ។ បើសិនជាគេសន្យាថា ស្មើប្រគល់ឱ្យវិញនោះគេត្រូវតែខំប្រឹងស្មើប្រគល់វាឱ្យវិញ។ បើសិនជាគេសន្យាថា នឹងប្រើប្រាស់វាសម្រាប់គោលដៅកំណត់ណាមួយនោះ គេត្រូវតែខំប្រឹងប្រើប្រាស់វាឱ្យត្រូវតាមគោលដៅនោះ។ ការគៃបន្លំអាចកើតឡើងតាមវិធីជាច្រើន ប៉ុន្តែរូបភាពទូទៅបំផុតអាចជាការបំផ្លាញទ្រព្យ ការលក់ទ្រព្យទៅឱ្យជនទីបី ការរក្សាវាទុក និងបដិសេធមិនព្រមប្រគល់ឱ្យវិញ ឬ មួយប្រើវាតាមគោលដៅផ្សេងៗទៀត ដែលខុសពីគោលដៅគ្រោងទុកដូចដែលបានព្រមព្រៀងគ្នា។

**ឧទាហរណ៍៖** ការគៃបន្លំ ទ្រព្យអាចកើតឡើង នៅពេលដែលនរណាម្នាក់បានខ្ចីម៉ូតូពីមិត្តភក្តិ រួចលក់ម៉ូតូនោះទៅឱ្យបុគ្គលទីបី។ ដូចគ្នានេះវាអាចកើតឡើងក្នុងស្ថានភាពដែលនិយោជិតម្នាក់បានទទួលប្រាក់ សម្រាប់យកទៅទិញគ្រឿងប្រើប្រាស់សម្រាប់ការិយាល័យ តែគេបែរជាយកប្រាក់នោះទៅចាក់ល្បែងភ្នាល់បាល់ទាត់ទៅវិញ។

ធាតុផ្សំនេះ ក៏តម្រូវឱ្យមានការខូចខាតដល់ម្ចាស់ទ្រព្យសម្បត្តិផងដែរ។ ការដែលជនជាប់ចោទបានថ្លោះធ្លោយ មិនបានបំពេញតាមការសន្យា វាមិនគ្រប់គ្រាន់ទេ។ ផ្ទុយទៅវិញ ការថ្លោះធ្លោយត្រូវតែកើតចេញពីការគៃបន្លំ ឬ ការចាត់ចែងលើទ្រព្យ ផ្ទុយពីផលប្រយោជន៍របស់ម្ចាស់ទ្រព្យនោះ។ ម្យ៉ាងទៀតការថ្លោះធ្លោយត្រូវមានលក្ខណៈថា ម្ចាស់របស់មិនអាចទទួលទ្រព្យបានមកវិញឡើយ។

**ឧទាហរណ៍៖** បើសិនជាស្ត្រីម្នាក់បានជួលរថយន្តមួយ សម្រាប់រយៈពេលមួយសប្តាហ៍ ហើយបានសងវាវិញយឺតជាងការសន្យាមួយថ្ងៃ នោះគាត់មិនបានគៃបន្លំយករថយន្តនោះទេ។ វាជាការពិតថា គាត់មិនអាចបំពេញតាមលក្ខខណ្ឌកំណត់ដ៏ជាក់លាក់នៃការសន្យាបានមែនប៉ុន្តែសកម្មភាពរបស់គាត់មិនបានធ្វើឱ្យខូចប្រយោជន៍ម្ចាស់ទ្រព្យដោយសាររថយន្តនោះទេ។ ស្ត្រីនោះអាចត្រូវបង់ថ្លៃជួលរថយន្ត មួយថ្ងៃថែមទៀត ប៉ុន្តែយោងតាមអត្ថន័យមាត្រា៩៦ គាត់មិនបានគៃបន្លំ ឬ បំបាត់ ឱ្យខូចប្រយោជន៍ លើ រថយន្តនោះទេ។ ក៏ប៉ុន្តែចំពោះបុរសម្នាក់ដែលជួលត្រាក់ទ័រ សម្រាប់រយៈពេលមួយសប្តាហ៍ ដើម្បីជីកដីនៅក្នុងភូមិកររបស់គាត់ ហើយបានលក់ត្រាក់ទ័រនោះ ទៅឱ្យជនទីបី ពិតជាគៃ បន្លំ

ត្រាក់ទ័រនោះមែនពីព្រោះម្ចាស់ទ្រព្យមិនអាចទទួលបានត្រាក់ទ័រពីជនជាប់ចោទមកវិញឡើយ។

### ៣.ធាតុអត្តនោម័តនៃបទរំលោភលើទំនុកចិត្ត

ធាតុអត្តនោម័តនៃបទល្មើស គឺជាផ្នែកខាងក្នុងនៃបទល្មើស សកម្មភាព ឬសភាវៈផ្លូវចិត្ត(សភាវៈនៃចិត្តសាស្ត្រ) របស់ប្រធាននៃបទល្មើសរួមមានៈ

- កំហុស( កំហុសចេតនា និង កំហុសអចេតនា)
- មូលហេតុនៃការប្រព្រឹត្តបទល្មើស
- គោលបំណងនៃការប្រព្រឹត្តបទល្មើស។[52]

នៅក្នុងអំពើដែលបានប្រព្រឹត្តរបស់ជនណាម្នាក់នៅក្នុង បទរំលោភលើទំនុកចិត្តចាំបាច់ណាស់ លុះត្រាតែអំពើនោះស្តែងចេញពីចេតនាទុច្ចរិតរបស់ជនល្មើស មានន័យថាជនល្មើសខកខានពុំបានបំពេញកាតព្វកិច្ចរបស់ខ្លួន ទៅលើម្ចាស់វត្ថុ។

**ឧទាហរណ៍៖** យុវជនម្នាក់ឈ្មោះ (ក) បានខ្ចីទូរស័ព្ទមិត្តស្រីរបស់គាត់ឈ្មោះកញ្ញា (ខ) ម៉ាក iPhon7 ដោយយុវជនឈ្មោះ (ក) បានសន្យាថានឹងប្រគល់ទូរស័ព្ទនេះទៅឱ្យកញ្ញា (ខ) វិញនៅរយៈពេលមួយថ្ងៃក្រោយ។ រយៈពេលមួយថ្ងៃកន្លងផុតទៅយុវជនឈ្មោះ (ក) ពុំបានយកទូរស័ព្ទទៅប្រគល់ជូនកញ្ញា (ខ) វិញទេ តែបែរជាយកទូរស័ព្ទនោះទៅលក់លេងល្បែងអស់ទៅ។

ប៉ុន្តែប្រសិនបើអ្នកខ្ចីទូរស័ព្ទម៉ាក iPhon7 បានធ្វើឱ្យទូរស័ព្ទនោះត្រូវ បាត់បង់ដោយមូលហេតុអំពើលួច ឬ ធ្វើឱ្យធ្លាក់បែក ឬ ខូចខាតដោយសារប្រការណាមួយ អ្នកខ្ចីទូរស័ព្ទម៉ាក iPhon7 នោះពុំមានចេតនាទុច្ចរិតទេ។ តាមអង្គហេតុនេះ ពុំមានបទល្មើសរំលោភលើទំនុកចិត្តឡើយ។

### ៤.ប្រធាននៃបទល្មើស

[52] សៀវភៅនីតិព្រហ្មទណ្ឌទូទៅខ្មែរ សាស្ត្រាចារ្យ កៅ សីហា ទំព័រ៣៤

ដូចយើងខ្ញុំបានបកស្រាយខាងលើរួចមកហើយអំពីប្រធាននៃបទល្មើសតែក្នុងករណីនេះយើងខ្ញុំសូមលើកយកមកពន្យល់បន្ថែមអំពីប្រធាននៃបទល្មើសដែលទាក់ទងទៅនឹងអំពើរបស់រូបវន្តបុគ្គលជានីតិជនតែប៉ុណ្ណោះ។

ជាទូទៅអំពើទាំងអស់ដែលបង្កើតបានជាបទល្មើស គឺកើតឡើងដោយសារអំពើរបស់មនុស្សប្រព្រឹត្តទៅលើមនុស្សដូចគ្នាដោយមានចេតនាទុច្ចរិត ហើយអំពើនោះត្រូវបានច្បាប់បានបញ្ញត្តិទុកជាមុនថាជាបទល្មើស ត្រូវផ្តន្ទាទោស។ នេះមិនមែនមានន័យថាគ្រប់អំពើរបស់មនុស្សទាំងអស់សុទ្ធតែបង្កើតបានជាបទល្មើសនោះទេ។ ជាក់ស្តែង បទរំលោភលើទំនុកចិត្តលុះត្រាតែជនល្មើសដែលត្រូវបានគេប្រគល់វត្ថុឱ្យ មានចេតនាទុច្ចរិតមិនចង់ប្រគល់ទ្រព្យសម្បត្តិឬ ធ្វើឱ្យខូចប្រយោជន៍ ទ្រព្យសម្បត្តិរបស់អ្នកដ៏ទៃទើបបង្កើតជាបទល្មើស។ ជាទូទៅប្រធាននៃបទល្មើស គឺជាមនុស្សពិតៗដែលបានប្រព្រឹត្តបទល្មើសហើយគ្រប់អាយុដែលច្បាប់បានបញ្ញត្តិឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ (អនីតិជន នីតិជន) និង មានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត។[53]

**កថាខណ្ឌទី៣.ជនដែលទទួលខុសត្រូវព្រហ្មទណ្ឌ**

**១.ចារី**

ចារីគឺ ជាបុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ ហើយត្រូវចោទប្រកាន់។ ត្រូវចាត់ទុកជាចារីផងដែរ ចំពោះជនដែលបានប៉ុនប៉ងប្រព្រឹត្តបទល្មើស។[54]

ឧទាហរណ៍៖ លោក ក បានវាយលោក គ មួយដំបូងបណ្តាលឱ្យបែកក្បាលហូរឈាមស្រោចខ្លួន អំពើរបស់លោក ក គឺជាបទល្មើសហិង្សាដោយចេតនា ដែលមានចែងនៅមាត្រា២១៧នៃក្រមព្រហ្មទណ្ឌ។ តាមអំពើរបស់លោក ក ត្រូវបានហៅថាជាចារីព្រោះប្រព្រឹត្តបទល្មើសដោយបានវាយលោក គ ។

**២.សហចារី**

[53] សៀវភៅរបស់ឯកឧត្តមបណ្ឌិត ហ៊ី សោភា នីតិព្រហ្មទណ្ឌមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទំព័រទី ៣៨

[54] មាត្រា២៥ នៃក្រមព្រហ្មទណ្ឌ

ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់។

ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក។[55]

ឧទាហរណ៍៖ ១. ក ខ និង គ បានព្រមព្រៀងគ្នាទៅវាយកម្ទេចរថយន្តរបស់គេដែលចតទុកមុខផ្ទះរបស់ខ្លួន ដូច្នេះអំពើរបស់ ក ខ និង គ គឺជាសហចារី។

**៣.អ្នកផ្ដើមគំនិត**

ត្រូវចាត់ទុកជាអ្នកផ្ដើមគំនិតក្នុងបទឧក្រិដ្ឋ ឬ មជ្ឈិមចំពោះបុគ្គលណា៖

- ជម្រុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះតាមការណែនាំ ឬការបញ្ជា។
- បង្កឱ្យមានបទឧក្រិដ្ឋ ឬមជ្ឈិមនោះ ដោយផ្ដល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬ ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។

អ្នកផ្ដើមគំនិតអាចត្រូវផ្ដន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬ បទមជ្ឈិមត្រូវសម្រេច ឬ ប៉ុនប៉ង។ អ្នកផ្ដើមគំនិតត្រូវផ្ដន្ទាទោសដូចគ្នានឹងអ្នកប្រព្រឹត្តបទល្មើសដែរ។

**ធាតុផ្សំសត្យានុម័តនៃការផ្ដើមគំនិត៖** សំដៅលើការជំរុញណែនាំ ឬបញ្ជា ដោយការបង្ក ដោយផ្ដល់អំណោយ ដោយការសន្យា ឬ ការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។

- **ធាតុអត្តនោម័តនៃការផ្ដើមគំនិត៖** អ្នកផ្ដើមគំនិតមានបំណងប្រព្រឹត្តអំពើ ផ្ដើមគំនិតមានន័យថា អ្នកផ្ដើមគំនិតដឹងថា អំពើរបស់ចារីគឺ ជាបទល្មើស ហើយខ្លួននៅតែមានចេតនាផ្ដើមគំនិតឱ្យបទល្មើសនេះកើតមានទៀត។[56]

**៤.អ្នកសមគំនិត**

[55] មាត្រា២៦ នៃក្រមព្រហ្មទណ្ឌ

[56] ឯកសារសិក្ខាសាលានីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ រៀបរាងដោយ សាស្ត្រាវុណ្ណារិទ្ធិ និងអ្នកគ្រូសាស្ត្រា ចាំង ស៊ី ណាត ទំព័រ១០៩

អ្នកសមគំនិត សំដៅលើបុគ្គលណាដែលជួយសម្រួលដោយចេតនា ដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។ ក្នុងលក្ខណៈប្រហាក់ប្រហែលនឹងការផ្តើមគំនិតដែរ ការសមគំនិតត្រូវបំពេញលក្ខខណ្ឌបីយ៉ាងដើម្បីអាចផ្តន្ទាទោសបានគឺៈ[57]

- អំពើចម្បងមានទោស
- ធាតុសត្យានុម័តៈ ការផ្តល់ជំនួយ ឬឧបត្ថម្ភ
- ធាតុអត្តនោម័តៈ អ្នកសមគំនិតដឹងថា អំពើរបស់ចារីជាបទល្មើស ហើយខ្លួននៅតែមានចេតនាផ្តល់ជំនួយ ឬឧបត្ថម្ភទៀត។

**កថាខណ្ឌទី៤.ទោសដែលត្រូវអនុវត្ត**

**១.ទោសធម្មតា**

បទល្មើសរំលោភលើទំនុកចិត្តដែលបានប្រព្រឹត្តដោយមិនចូលទៅក្នុងលក្ខខណ្ឌស្ថានទម្ងន់ទោសណាមួយដូចដែលបានចែងនៅមាត្រា៣៩៤គឺ ត្រូវអនុវត្តទោសជាធម្មតាចំពោះ បទរំលោភលើទំនុកចិត្តគឺ តុលាការអនុលោមទៅតាមមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩។ នៅក្នុងអត្ថន័យខ្លឹមសាររបស់មាត្រានេះបានចែងកំណត់ថា អំពើរំលោភលើទំនុកចិត្ត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។[58]

**ឧទាហរណ៍**ៈ លោក **ក** បុគ្គលិកក្រុមហ៊ុនលក់ថ្នាំពេទ្យមួយ។ នៅថ្ងៃមួយក្រុមហ៊ុនតម្រូវ ឱ្យលោក **ក** យកថ្នាំពេទ្យទៅឱ្យ Pharmacy មួយដែលបញ្ជាទិញ។ លោក **ក** មិនបានយកថ្នាំនោះទៅឱ្យ Pharmacy ដែលបានបញ្ជាទិញនោះទេ បែរជាយកទៅលក់ឱ្យ Pharmacy ផ្សេងហើយយកលុយនោះទៅចាយវាយអស់ទៅ។

**២.ស្ថានទម្ងន់ទោស**

[57] ឯកសារសិក្ខាសាលានីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ រៀបរាងដោយ សាស្ត្រាវុណ្ណារិទ្ធិ និងអ្នកគ្រូសាស្ត្រា ចាំង ស៊ី ណាត ទំព័រ១០៩

[58] មាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ

អំពើរំលោភលើទំនុកចិត្ត ត្រូវផ្តន្ទាទោសដាក់ពន្ធធាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើបទល្មើសនេះបានប្រព្រឹត្តឡើង៖

**ស្ថានទម្ងន់ទោសទាក់ទងនឹងជនល្មើស**

១.ដោយបុគ្គលណាម្នាក់ដែលបានធ្វើការអំពាវនាវដល់សាធារណៈជន ដើម្បីទទួលបានមូលនិធិ ឬតម្លៃសម្រាប់ជាប្រយោជន៍ផ្ទាល់ ឬ ជាប្រយោជន៍របស់សហគ្រាសឧស្សាហកម្មពាណិជ្ជកម្ម។

**ឧទាហរណ៍៖** ប្រធានក្រុមហ៊ុនជីកសិកម្មមួយបានចាត់ឱ្យលោក (A) ចុះទៅជនបទដើម្បីធ្វើការផ្សព្វផ្សាយពីអត្ថប្រយោជន៍របស់ជីកសិកម្ម និងសេវាដឹកជញ្ជូនដោយឥតគិតថ្លៃដល់ប្រជាពលរដ្ឋដែលធ្វើស្រែចំការ។ បន្ទាប់ពីបានយល់ដឹងពីអត្ថប្រយោជន៍របស់ជីកសិកម្មនោះហើយប្រជាពលរដ្ឋក៏មានចំណាប់អារម្មណ៍ចង់ប្រើប្រាស់ជីកសិកម្មនោះណាស់ដើម្បីឱ្យដំណាំរបស់ពួកគេទទួលបានផលល្អ។ ផ្ទុយទៅវិញដោយគំនិតទុច្ចរិតលោក (A) បាននិយាយទៅកាន់ប្រជាពលរដ្ឋថា បើអ្នកទាំងអស់គ្នាចង់ប្រើប្រាស់ជីកសិកម្មនេះត្រូវបង់លុយមកឱ្យក្រុមហ៊ុនតាមរយៈខ្ញុំដោយម្នាក់ៗបង់ត្រឹមតែ ១០$ តែប៉ុណ្ណោះនោះក្រុមហ៊ុន និងដឹកជញ្ជូនដល់ផ្ទះតែម្តង។

២. ដោយអាណត្តិគាហករបស់តុលាការ ឬ អ្នកជំនួយរបស់តុលាការ នៅក្នុងក្របខណ្ឌនៃមុខងាររបស់ខ្លួន ឬ នៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។

**ឧទាហរណ៍៖** លោក (B) ជាជំនួយការរបស់មេធាវីដែលបានបំពេញភារកិច្ចរត់ឯកសារលើរឿងក្តីឱ្យមេធាវី។ ថ្ងៃមួយលោក (ក) ជាជនរងគ្រោះបានមកពឹងពាក់លោកមេធាវីឱ្យជួយការពាររឿងក្តីរបស់ខ្លួន។ ដោយលោក (B) ជាអ្នករត់ឯកសារ ខ្លួនក៏បានកេងចំណេញប្រាក់ពីលើសេវារបស់លោកមេធាវី។

៣. ដោយអ្នករាជការសាធារណៈ នៅក្នុងក្របខណ្ឌនៃមុខងាររបស់ខ្លួន ឬ នៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។[59]

[59] មាត្រា ៣៩៤ នៃក្រមព្រហ្មទណ្ឌ

**ឧទាហរណ៍៖** មេប៉ូលីសចរាចរណ៍មួយរូបឈ្មោះលោក (ខ) បានធ្វើការផាកពិន័យប្រជាពលរដ្ឋជាច្រើននាក់ ដែលបើកបរមិនគោរពច្បាប់ចរាចរណ៍ ផ្លាកសញ្ញា ភ្លើងសញ្ញា និងគំនូសចរាចរណ៍។ លោក (ខ) បន្ទាប់ពីបញ្ចប់ភារកិច្ចម៉ោងធ្វើការរបស់ខ្លួនរួចរាល់ហើយ លោក (ខ) បានកិបកេងលុយអង្គភាពរបស់ខ្លួន។

**៣.ទោសបន្ថែម**

ចំពោះខ្លឹមសារនៃទោសបន្ថែមទូទៅយើងខ្ញុំបានបកស្រាយនៅផ្នែកទី១ កថាខណ្ឌទី៤ ចំណុច៤ ខាងលើរួចហើយដូច្នេះយើងខ្ញុំមិនបានបកស្រាយម្តងទៀតទេ។ ចំពោះទោសបន្ថែម នៃបទរំលោភលើទំនុកចិត្តមានចំនួន១០ចំណុច ដែលត្រូវយកទៅប្រកាសចំពោះទណ្ឌិតដែលបានប្រព្រឹត្តល្មើស ហើយ១០ ចំណុចនេះចៅក្រមអាចយកទៅប្រកាស ១ ឬច្រើនចំណុចទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន ឬក៏អាចយកទោសបន្ថែមនេះទៅប្រកាសជំនួសមូលទោសក៏បាន។ **ទោសបន្ថែមទាំង១០ចំណុចនេះយើងខ្ញុំនឹងធ្វើការបកស្រាយនៅក្នុងជំពូកទី២ កថាខណ្ឌទី១ ចំណុច៤។**

**៤.ការប៉ុនប៉ង**

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នា និង បទមជ្ឈិមខាងលើដែរ។[60]

**ឧទាហរណ៍៖** លោក (ក) បានខ្ចីម៉ូតូមិត្តភក្តិរបស់គាត់ឈ្មោះលោក (ខ) ទៅចូលរួមកម្មវិធីជប់លៀងនៅភ្នំពេញ។ បន្ទាប់ពីចប់កម្មវិធីរួចរាល់លោក (ក) មិនបានត្រឡប់ទៅផ្ទះវិញទេ គាត់ក៏បានចូលខារ៉ាអូខេនៅកន្លែងទំនើបមួយកន្លែង ជាមួយមិត្តភក្តិដល់យប់ជ្រៅ តែដោយសារខ្វះលុយនិង សភាពស្រវឹងស្រាផងនោះ លោក (ក) ក៏សម្រេចចិត្តយកម៉ូតូរបស់លោក (ខ) ទៅលក់នៅកន្លែងមួយ គាប់ជួនមានក្រុមសមត្ថកិច្ចត្រួតពិនិត្យគ្រឿងស្រវឹង និងគ្រឿងញៀនពេលយប់ បានឃាត់ម៉ូតូលោក (ក) កំពុងជិះហើយបានធ្វើការឆែកឆេរ តែដោយសារតែម៉ូតូដែលគាត់យកទៅលក់គ្មាន កាតគ្រី ទើបសមត្ថកិច្ចកំណត់មុខសញ្ញារង់ចាំការសាកសួរ។

[60] មាត្រា៣៩៥ នៃក្រមព្រហ្មទណ្ឌ

ចំពោះឧទាហរណ៍ខាងលើនេះ អំពើរបស់លោក (ក) ដែលមានចេតនាទុច្ចរិតចង់យកម៉ូតូរបស់លោក (ខ) ទៅលក់តែដោយសារឥទ្ធិពលក្រៅឆន្ទៈរបស់ខ្លួនមករារាំង ដោយគាត់មិនបានបញ្ឈប់សកម្មភាពយកម៉ូតូរបស់លោក (ខ) ទៅលក់ដោយខ្លួនឯងទេ ពោលគឺមានក្រុមសមត្ថកិច្ចត្រួតពិនិត្យគ្រឿងស្រវឹង និងគ្រឿងញៀនពេលយប់ បានឃាត់ម៉ូតូលោក (ក) កំពុងជិះ តែដោយសារសមត្ថកិច្ចមានការសង្ស័យថា និងមានការជាប់ពាក់ព័ន្ធទៅនឹងបទល្មើសណាមួយ ទើបសមត្ថកិច្ចធ្វើការសាកសួរ។ បន្ទាប់ពីធ្វើការសាកសួររួចរាល់ហើយ និងស្វែងរកម្ចាស់ម៉ូតូ(លោក ខ )ឃើញហើយនោះ សមត្ថកិច្ចបានចោទប្រកាន់លោក (ក)ពីបទប៉ុនប៉ងរំលោភលើទំនុកចិត្ត។

**កថាខណ្ឌទី៥.បទរំលោភលើទំនុកចិត្តពិសេស**

បទរំលោភលើទំនុកចិត្តពិសេស គឺសំដៅដល់គ្រប់អភិបាល ឬ អ្នកត្រួតពិនិត្យរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលមូលនិធិ ឬ បុគ្គលដែលត្រូវបានតុលាការចាត់តាំងឱ្យធ្វើជំនួសនូវកិច្ចការរបស់អ្នកទាំងនេះ ឬនិយោជិតដែលទទួលអាណត្តិពីនីតិបុគ្គល ដែលប្រព្រឹត្តអំពើណាមួយដែលជាការរំលោភលើទំនុកចិត្ត ក្នុងគោលបំណងទទួលផលប្រយោជន៍ដល់ខ្លួន ឬ តតិយជន ឬ ក្នុងគោលបំណងធ្វើឱ្យខូចខាតដល់នីតិបុគ្គល ហើយបានបណ្តាលឱ្យមានការខូចខាតទ្រព្យសម្បត្តិរបស់នីតិបុគ្គលនោះ។

**ឧទាហរណ៍៖** លោក (C) ជាបុគ្គលិករបស់ក្រុមហ៊ុនផលិតទឹកត្រីមួយនៅរាជធានីភ្នំពេញ ។ ដោយសារតែរសជាតិឆ្ងុយឆ្ងាញ់អតិថិជនបានធ្វើការកម្មង់ទឹកត្រីយ៉ាងច្រើនដើម្បីទៅលក់បន្តនៅតាមដេប៉ូចែកចាយមិនថារាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។ លោក (C) ត្រូវបាននិយោជករបស់ខ្លួនប្រើឱ្យបើករថយន្តដឹកទឹកត្រីទៅលក់តាមដេប៉ូនានាជារៀងរាល់ថ្ងៃ និងត្រូវគិតលុយពីអតិថិជនផង។ ពេលដែលប្រមូលលុយពីអតិថិជនរួចរាល់ លោក (C) បានកិបកេងលុយក្រុមហ៊ុន ជាច្រើនលើកច្រើនសារ ដោយលោក (C) ធ្វើរបាយការណ៍កុហកដោយលក់បានប៉ុណ្ណោះ ក្នុងរបាយការណ៍ថាលក់បានប៉ុណ្ណេះ។ ក្រុមហ៊ុនចេះតែបាត់ចំណូលរៀងរាល់ខែ ទីបំផុតទើបដឹងថាលោក (C) ជាអ្នកកេងចំណេញលុយរបស់ក្រុមហ៊ុនដោយធ្វើរបាយការណ៍ភូតកុហក។

ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកជម្រះបញ្ជីរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលមូលនិធិ ឬ បុគ្គលដែលត្រូវបានតុលាការជ្រើសតាំងឱ្យធ្វើជំនួសនូវកិច្ចការរបស់អ្នកជម្រះ បញ្ជីបានប្រព្រឹត្តអំពើដូចបានកំណត់ ខាងលើនេះ ហើយបានបណ្ដាលឱ្យមានការខូចខាតទ្រព្យសម្បត្តិរបស់នីតិបុគ្គលនោះ។

ការប៉ុនប៉ងប្រព្រឹត្តបទល្មើសដែលបានបកស្រាយ ខាងលើនេះ និងត្រូវផ្ដន្ទាទោសដូចគ្នាដែរ។

**១.ប្រធាននៃបទរំលោភលើទំនុកចិត្តពិសេស**

បទរំលោភលើទំនុកចិត្តពិសេសប្រធាននៃបទល្មើសរួមមាន៖ គ្រប់អភិបាល អ្នកត្រួតពិនិត្យរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលមូលនិធិ ឬ បុគ្គលដែលត្រូវតុលាការជ្រើសតាំងធ្វើឱ្យជំនួយនូវកិច្ចការរបស់អ្នកទាំងនេះ ឬ និយោជិតដែលទទួលអាណត្តិពីនីតិបុគ្គល ដែលប្រព្រឹត្តអំពើណាមួយដែលជាការរំលោភលើទំនុកចិត្ត។

**២.ទោសដែលត្រូវអនុវត្ត**

បទរំលោភលើទំនុកចិត្តពិសេស ត្រូវផ្ដន្ទាទោសដាក់ពន្ធ ពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។[61]

[61] មាត្រា៣៩៣ នៃក្រមព្រហ្មទណ្ឌ

## ជំពូកទី២.ការប្រៀបធៀបបទល្មើសទាំងពីរ

បន្ទាប់ពីបានឆ្លងកាត់ការបកស្រាយបទល្មើសទាំងពីររួចមកយើងឃើញថា បទល្មើសទាំងពីរនេះគឺ មានសញ្ញាណមួយចំនួនដែលមានលក្ខណៈដូចគ្នា និងខុសគ្នាដែលអាចឱ្យយើងយកមកធ្វើការប្រៀបធៀបគ្នាបាន។

### ផ្នែកទី១.ចំណុចដូចគ្នារវាងបទល្មើសទាំងពីរ

ជាការពិតណាស់រាល់បទល្មើសនីមួយៗដែលបានបញ្ញត្តិនៅក្នុងគន្ថីទី៣នេះគឺ តែងតែមាន លក្ខណៈមួយចំនួនដែលដូចគ្នា និងមួយចំនួនទៀតខុសគ្នា។ ជាក់ស្តែងដូចជាបទល្មើសទាំងពីរនេះគឺមានលក្ខណៈដូចគ្នាផង និងមានលក្ខណៈខុសគ្នាមួយចំនួនដូចជា៖

#### កថាខណ្ឌទី១.ធាតុនីត្យានុកូល

ធាតុនីត្យានុកូលនៃបទល្មើសគឺ សំដៅទៅលើការដែលបានចែងនៅក្នុងមាត្រាណាមួយនៃក្រមព្រហ្មទណ្ឌនូវអំពើណាមួយ ត្រូវបានកំណត់ថាជាបទល្មើស។ បន្ទាប់ពីបានបកស្រាយពីចំណុចនេះហើយយើងត្រូវមើលបទប្បញ្ញត្តិ នៃក្រមព្រហ្មទណ្ឌ ដោយផ្តោតសំខាន់ទៅលើបទល្មើសទាំងពីរ។ ក្រមព្រហ្មទណ្ឌត្រូវបាននីតិករតាក់តែងឡើងដោយមានរចនាសម្ព័ន្ធរៀបចំឱ្យមានជាលំដាប់ដូចជា គន្ថី ជំពូក ផ្នែក និងមាត្រាជាដើមដូចជា៖

**១.ចែងនៅក្នុងគន្ថី**

ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាត្រូវបានបែងចែកជា ៦គន្ថី ហើយមានតែបីគន្ថីប៉ុណ្ណោះ ដែលបានកំណត់អំពីបទល្មើសហើយគន្ថីទាំងនោះរួមមានគន្ថីទី២ និយាយអំពីបទល្មើសប្រឆាំងនឹងបុគ្គល គន្ថីទី៣ បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ និងគន្ថីទី៤ បទល្មើសប្រឆាំងនឹងជាតិ។ ចំពោះបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្តវិញគឺ មានចែងនៅក្នុងគន្ថីទី៣ និយាយអំពីបទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ។ កត្តាដែលធ្វើឱ្យនីតិករដាក់បទល្មើសទាំងពីរនេះនៅក្នុងគន្ថីតែមួយព្រោះតែបទល្មើសទាំងពីរទាក់ទងនឹងទ្រព្យសម្បត្តិដូចគ្នា ហើយធ្វើឱ្យប៉ះពាល់ដល់កម្មសិទ្ធិរបស់បុគ្គល រួមមានទ្រព្យសម្បត្តិ ឬ វត្ថុមានតម្លៃផ្សេងៗដូចគ្នាជាដើម។

**១.១ចែងនៅក្នុងមាតិកា**

នីតិករបានរៀបរៀងចងក្រងក្រមនេះឡើងទៅតាមរចនាសម្ព័ន្ធ និងបែបបទដើម្បីឱ្យងាយស្រួលក្នុងការស្វែងយល់អំពីច្បាប់នេះ។ នៅក្នុងគន្ថីនេះនីតិករបានបែងចែកជាមាតិកា ហើយមាតិកានេះគឺជាចំណុចមួយដែលជាលំដាប់បន្ទាប់ពីគន្ថី។ ហើយនៅក្នុងគន្ថីខ្លះមានមាតិកាច្រើន ឬតិចវាអាស្រ័យទៅលើវិសាលភាពនៃគន្ថីនោះ។ ចំណែកឯបទល្មើសទាំងពីរវិញគឺ មានចែងនៅក្នុងមាតិកា១ និយាយអំពីការយកទ្រព្យសម្បត្តិអ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយទុច្ចរិត។

**១.២ធាតុនីត្យានុកូលនៃទោស**

គោលការណ៍នីត្យានុកូល នៃទោសគឺមាននៅក្នុងគោលការណ៍នីត្យានុកូលនៃបទល្មើសនេះតែម្តង ហើយគោលការណ៍នីត្យានុកូល នៃទោសនេះគឺ មានតែទោសដែលមានចែងនៅក្នុងក្រមជាធរមានប៉ុណ្ណោះ ទើបអាចប្រកាស និងផ្តន្ទាទោសបាន។ ហើយទោសដែលត្រូវប្រកាសចំពោះបទល្មើសទាំងពីរគឺ ផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ទៅ ៣ (បី)ឆ្នាំ និងពិន័យជាប្រាក់ពី១០០០០០០ (មួយលាន) រៀល ទៅ ៦០០០០០០ (ប្រាំមួយលាន) រៀល។

**១.៣កំណត់ការប៉ុនប៉ងមានទោស**

ច្បាប់បានកំណត់អំពីការប៉ុនប៉ងរវាងបទល្មើសឆបោក និងបទរំលោភលើទំនុកចិត្តគឺ ត្រូវផ្តន្ទាទោសដូចគ្នាចំពោះបទល្មើសបានសម្រេចផងដែរ។ ជាគោលការណ៍ការប៉ុនប៉ងអាចត្រូវផ្តន្ទាទោសបានចំពោះបទល្មើសមជ្ឈិម។

លុះត្រាតែច្បាប់បានចែងកំណត់អំពីការប៉ុនប៉ង នៃបទល្មើសជាមុនសិន ទើបតុលាការអាចប្រកាសផ្តន្ទាទោសពីការប៉ុនប៉ងនោះបាន។ ការប៉ុនប៉ងចំពោះបទល្មើសឆបោកត្រូវចែងកំណត់នៅមាត្រា៣៨១ ចំណែកឯបទល្មើសរំលោភលើទំនុកចិត្តវិញការប៉ុនប៉ងត្រូវចែងនៅមាត្រា៣៩៥។

**កថាខណ្ឌទី២.ចំណាត់ថ្នាក់នៃបទល្មើស**

ជាគោលការណ៍បទល្មើសព្រហ្មទណ្ឌត្រូវបានបែងចែកជាបីថ្នាក់ ដែលមានចែងកំណត់យ៉ាងច្បាស់លាស់នៅក្នុងក្រមព្រហ្មទណ្ឌត្រង់មាត្រា២ វាក្យខណ្ឌទី២ ដែលបានចែង

ថា បទល្មើសត្រូវបានចាត់ថ្នាក់ជាបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុទៅតាមស្ថានទម្ងន់នៃបទល្មើស។

- បទល្មើសជាបទឧក្រិដ្ឋ នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវទទួលរងនោះ[62]៖
  - ជាទោសដាក់ពន្ធនាគារអស់មួយជីវិត
  - ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី៥ឆ្នាំ ឬ ក្រោមឬស្មើ ៣០ឆ្នាំ។ ហើយទោសនេះអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។
- បទល្មើសជាបទមជ្ឈិម[63]៖

  បទល្មើសជាបទមជ្ឈិមនៅក្នុងករណីដែលអតិបរមា នៃទោសដាក់ពន្ធនាគារ ដែលត្រូវរងនោះ មានរយៈពេលលើសពី៦ថ្ងៃ ដល់ក្រោម ឬស្មើ ៥ឆ្នាំ។
- បទល្មើសជាបទលហុ[64]៖
  - អតិបរមា នៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះមានរយៈពេលស្មើ ឬក្រោម៦ថ្ងៃ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។
  - បទល្មើសត្រូវផ្ដន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ។

ចំពោះបទល្មើសទាំងពីរត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារចន្លោះពី៦ខែ ទៅ ៣ឆ្នាំ ដូច្នេះត្រូវស្ថិតនៅក្នុងចំណាត់ថ្នាក់នៃបទមជ្ឈិម ព្រោះអតិបរមា នៃទោសពន្ធនាគារមិនលើសពី៥ឆ្នាំទេ។ បើយោងទៅតាមមាត្រា៤៧ នៃក្រមនេះ បានឱ្យនិយមន័យថា បទល្មើសជាបទមជ្ឈិម នៅក្នុងករណីដែលអតិបរមា នៃទោសដាក់ពន្ធនាគារ ដែលត្រូវរងនោះ មានរយៈពេលលើសពី៦ថ្ងៃ ដល់ក្រោម ឬស្មើ ៥ឆ្នាំ។

[62] មាត្រា៤៦ នៃក្រមព្រហ្មទណ្ឌ

[63] មាត្រា៤៧ នៃក្រមព្រហ្មទណ្ឌ

[64] មាត្រា៤៨ នៃក្រមព្រហ្មទណ្ឌ

**កថាខណ្ឌទី៣.អាជ្ញាយុកាល**

**១.អាជ្ញាយុកាលនៃបទល្មើស**

អាជ្ញាយុកាលគឺជារយៈពេលមួយដែលច្បាប់កំណត់ នៃការទទួលខុសត្រូវ ឬមិនទទួលខុសត្រូវចំពោះមុខច្បាប់។ អាជ្ញាយុកាលនៃបទល្មើសត្រូវបានគេបែងចែកជាបីទៀតគឺ[65]៖

- អាជ្ញាយុកាល នៃបទល្មើសឧក្រិដ្ឋមានរយៈពេល១៥ឆ្នាំ
- អាជ្ញាយុកាល នៃបទល្មើសមជ្ឈិមមានរយៈពេល៥ឆ្នាំ
- អាជ្ញាយុកាល នៃបទល្មើសលហុមានរយៈពេល១ឆ្នាំ

ចំពោះអាជ្ញាយុកាល នៃបទល្មើសគឺជារយៈពេលមួយដែលត្រូវរាប់ ឬគិតចាប់ពីពេលបទល្មើសត្រូវបានប្រព្រឹត្តទោះបានសម្រេច ឬមិនបានសម្រេច។[66] ចំពោះអាជ្ញាយុកាល នៃបទល្មើសទាំងពីរគឺ មានអាជ្ញាយុកាលរយៈពេល៥ឆ្នាំ ដោយរាប់ចាប់ពីពេលបទល្មើសបានប្រព្រឹត្តចប់។

**២.អាជ្ញាយុកាលនៃទោស**

អាជ្ញាយុកាលនៃទោសគឺ ជាថេរវេលាមួយដែលត្រូវរាប់ចាប់ពីពេលដែលទោសត្រូវប្រកាសដោយចៅក្រមហើយទោសនោះបានចូលជាស្ថាពរ។ ហើយទោសដែលត្រូវបានប្រកាសនោះផុតរយៈពេលដែលកំណត់ដោយច្បាប់នេះ មិនអាចយកទោសនោះទៅអនុវត្តបានទៀតឡើយ។[67] ហើយអាជ្ញាយុកាលនៃទោសត្រូវបានបែងចែកជាបីដូចជា៖

- អាជ្ញាយុកាលនៃបទឧក្រិដ្ឋមានរយៈពេល២០ឆ្នាំ
- អាជ្ញាយុកាលនៃបទមជ្ឈិមមានរយៈពេល៥ឆ្នាំ
- អាជ្ញាយុកាលនៃបទលហុមានរយៈពេល១ឆ្នាំ

[65] មាត្រា១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[66] មាត្រា១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[67] មាត្រា១៩៥ នៃក្រមព្រហ្មទណ្ឌ

ចំណែកឯបទល្មើសឆបោក និងរំលោភលើទំនុកចិត្តវិញ អាជ្ញាយុកាលនៃទោសគឺ មានរយៈពេល៥ឆ្នាំ ដោយរាប់ពីពេលដែលសាលក្រមបានចូលជាស្ថាពរ។[68]

**កថាខណ្ឌទី៤.ធាតុអត្តនោម័ត**

ជនល្មើសគឺបានប្រព្រឹត្តអំពើល្មើសដោយចេតនា ដោយខ្លួនបានប្រើល្បិចធ្វើឱ្យជនរងគ្រោះប្រគល់នូវទ្រព្យសម្បត្តិ ឬវត្ថុមានតម្លៃផ្សេងៗមកឱ្យខ្លួន។ ហើយជនល្មើសបានដឹងយ៉ាងច្បាស់អំពីអំពើរបស់ខ្លួនដែលបានប្រព្រឹត្តគឺ ជាអំពើដែលច្បាប់បានហាមឃាត់។

**ផ្នែកទី២.ចំណុចខុសគ្នារវាងបទល្មើសទាំងពីរ**

**កថាខណ្ឌទី១.ធាតុនីត្យានុកូលនៃបទល្មើសទាំងពីរ**

**១.និយមន័យនៃបទល្មើស**

ជាការពិតណាស់បទល្មើសនីមួយៗក្រមព្រហ្មទណ្ឌតែងតែឱ្យនិយមន័យច្បាស់លាស់ណាស់ដើម្បីងាយយល់ពីស្ថានភាព នៃបទល្មើសណាមួយដែលកំណត់នៅក្នុងក្រមព្រហ្មទណ្ឌ។ ចំពោះបទល្មើសទាំងពីរនេះក្រមក៏បានឱ្យនិយមន័យយ៉ាងច្បាស់ផងដែរ។

**បទល្មើសឆបោក** គឺជាអំពើបន្លំចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដោយប្រើឈ្មោះក្លែងដោយអះអាងទៅលើឋានៈក្លែង ដោយរំលោភលើឋានៈពិតប្រាកដ ឬ ដោយប្រើឧបាយកលទុច្ចរិត ហើយដូច្នេះបានទទួលពីបុគ្គលនេះ ដែលនាំឱ្យខូចប្រយោជន៍របស់បុគ្គលនេះ ឬរបស់តតិយជននូវៈ

១.ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ។

២.ការផ្ដត់ផ្គង់សេវា។

៣.ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬ ជាការឱ្យរួចពីកាតព្វកិច្ច[69]។

**ចំណែកឯបទល្មើសរំលោភលើទំនុកចិត្ត** អំពើរំលោភលើទំនុកចិត្តគឺ ជាអំពើតែបំបាត់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ នាំឱ្យខូចប្រយោជន៍អ្នកដទៃ ប្រព្រឹត្តដោយបុគ្គលណាម្នាក់ ដែលគេបានប្រគល់ឱ្យបុគ្គលនោះ ហើយបុគ្គលនោះ បានយល់ព្រមដោយ

---

[68] មាត្រា១៩៤ នៃក្រមព្រហ្មទណ្ឌ

[69] មាត្រា៣៧៧ នៃក្រមព្រហ្មទណ្ឌ

មានភារកិច្ចប្រគល់សងវិញ បង្ហាញឬ យកមូលនិធិតម្លៃ ឬទ្រព្យសម្បត្តិនោះទៅធ្វើការប្រើប្រាស់ជាកំណត់។[70]

**២.ចែងនៅក្នុងមាត្រា**

ក្រមព្រហ្មទណ្ឌត្រូវបានបែងចែកជា ៦គន្ថី នៅក្នុងចំណោម៦គន្ថីនោះត្រូវបានបែងចែកជាមាតិកា ជំពូក ផ្នែក មាត្រាទៀត ហើយនៅក្នុងក្រមព្រហ្មទណ្ឌមានចំនួន៦៧២មាត្រា។ ចំណែកបទល្មើសទាំងពីរវិញត្រូវបានចែងដាច់ពីគ្នារវាងបទល្មើសឆបោក និងបទល្មើសរំលោភលើទំនុកចិត្ត។

**បទល្មើសឆបោក** នីតិករបានចែងនៅមាត្រា៣៧៧ នៃក្រមព្រហ្មទណ្ឌនិយាយអំពីនិយមន័យនៃបទល្មើសឆបោក និងទោសដែលត្រូវអនុវត្តមានចែងនៅមាត្រា៣៧៨ ហើយទោសផ្សេងៗទៀតដូចជាស្ថានទម្ងន់ទោស និងទោសបន្ថែមមានចែងចាប់ពី៣៧៩-៣៨២នៃក្រមព្រហ្មទណ្ឌ។

**ចំពោះបទល្មើសរំលោភលើទំនុកចិត្ត**វិញគឺ មានចែងចាប់ពីមាត្រា៣៩១ និយាយអំពីនិយមន័យនៃបទល្មើស ហើយទោសដែលត្រូវអនុវត្តចំពោះបទល្មើសនេះ មានចាប់ពីមាត្រា៣៩២ រហូតដល់មាត្រា៣៩៦ នៃក្រមនេះបូករួមទាំងស្ថានទម្ងន់ទោស និងទោសបន្ថែមចំពោះបទល្មើសរំលោភលើទំនុកចិត្ត។

**៣.ស្ថានទម្ងន់ទោស**

រាល់ការប្រព្រឹត្តបទល្មើសនីមួយៗតែងមានស្ថានភាពនៃការប្រព្រឹត្តផ្សេងគ្នា ដូច្នេះហើយទើបនីតិករបានតាក់តែងកំណត់ស្ថានភាពណាមួយ នៃការប្រព្រឹត្តបទល្មើស ចូលទៅក្នុងស្ថានភាពឃោរឃៅ ព្រៃផ្សៃ ឬស្ថានភាពណាមួយដែលជាស្ថានទម្ងន់ទោស នៃបទល្មើសនោះ។ ហើយស្ថានទម្ងន់ទោសណាមួយអាចយកទៅប្រកាសបានលុះត្រា តែស្ថានទម្ងន់ទោសនោះត្រូវបានចែងកំណត់នៅក្នុងបទល្មើសទាំងនោះច្បាស់លាស់ទើបចៅក្រមអាចយកទៅប្រើប្រាស់ក្នុងការប្រកាសទោសចំពោះជនល្មើសបាន។

---

[70] មាត្រា ៣៩១ នៃក្រមព្រហ្មទណ្ឌ

**បទល្មើសឆបោក** គឺមានស្ថានទម្ងន់ទោសពីរដែលបានចែងកំណត់យ៉ាងច្បាស់លាស់នៅមាត្រា៣៧៩ និយាយអំពីស្ថានទម្ងន់ទោសដែលទាក់ទងទៅនឹងជនរងគ្រោះ ហើយ និងស្ថានទម្ងន់ទោសផ្សេងៗទៀត ដែលបានចែងនៅមាត្រា៣៨០នៃក្រមនេះ។

**បទល្មើសរំលោភលើទំនុកចិត្ត** មានស្ថានទម្ងន់ទោស តែមួយប៉ុណ្ណោះដែលបានចែងនៅក្នុងមាត្រា៣៩៦ និយាយអំពីស្ថានទម្ងន់ទោសទោសដែលទាក់ទងទៅនឹងជនល្មើស។

**៤.ទោសបន្ថែម**

ទោសបន្ថែមក៏ដូចជាស្ថានទម្ងន់ទោសដែរ អាចយកទៅប្រកាសបានលុះត្រាតែមានចែងបន្ថែមនៅក្នុងជំពូកឬផ្នែកយ៉ាងច្បាស់នៃបទល្មើសនោះ ទើបចៅក្រមអាចយកទោសបន្ថែមនោះ ទៅប្រកាសបាន។ ហើយទោសបន្ថែមនេះតុលាការអាចយកទៅប្រកាស ១ ឬច្រើនបន្ថែមទៅលើមូលទោសទៅតាមការយល់ឃើញ ឬឆន្ទានុសិទ្ធិរបស់ចៅក្រម។

**បទល្មើសឆបោក** ទោសបន្ថែមត្រូវបានកំណត់នៅមាត្រា៣៨២ នៃក្រមនេះមានចំនួន ១៣ចំណុចសម្រាប់យកទៅប្រកាសចំពោះបទល្មើសឆបោកនេះរួមមាន៖

១. ការដកសិទ្ធិខ្លះជាប្រជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល៥ឆ្នាំយ៉ាងច្រើន។

២. ការហាមឃាត់ការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកវិជ្ជាជីវៈ ឬនៅក្នុងឱកាស នៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ សម្រាប់រយៈពេល៥ឆ្នាំយ៉ាងច្រើន។

៣. ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល៥ឆ្នាំ យ៉ាងច្រើន ចំពោះបទមជ្ឈិម។

៤. ការហាមឃាត់ចំពោះទណ្ឌិតបរទេសចំពោះការចូល ឬ ការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។

៥. ការរឹបអូសឧបករណ៍ សម្ភារ ឬ វត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស។

៦. ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាកម្មវត្ថុ នៃបទល្មើស។

៧. ការរឹបអូសផលទុន និងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

៨. ការរឹបអូសឧបភោគភណ្ឌ សម្ភារ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបានប្រព្រឹត្ត។

៩. ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង។

១០.ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។

១១.ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែយ៉ាងច្រើន។

១២.ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

១៣.ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃយ៉ាងច្រើន។

**បទរំលោភលើទំនុកចិត្ត** ទោសបន្ថែមគឺមាន ១០ចំណុចរួមមាន៖

១. ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។

២. ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាស នៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥(ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៣. ការរឹបអូសឧបករណ៍សម្ភារ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស។

៤. ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាកម្មវត្ថុ នៃបទល្មើស។

៥. ការរឹបអូសផលទុន និង ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

៦. ការរឹបអូសឧបភោគភណ្ឌ សម្ភារ ឬ ចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសនោះបានប្រព្រឹត្ត។

៧. ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង។

៨.ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសសម្រាប់រយៈពេល ២(ពីរ)ខែ យ៉ាងច្រើន

៩. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

១០. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន។

**៣.ចែងនៅក្នុងជំពូក**

ដូចដែលបានបកស្រាយខាងលើរួចមកហើយថាក្រមព្រហ្មទណ្ឌត្រូវបានបែងចែកទៅតាមលំដាប់ដូចជាគន្ថី មាតិកា ផ្នែក ជំពូក និងមាត្រាដើម្បីងាយស្រួលក្នុងការសិក្សា និងការអនុវត្ត។ បទល្មើសឆបោក និងបទរំលោភលើទំនុកចិត្តគឺ ជាបទល្មើសមួយដែលមានចែងនៅក្នុងគន្ថីទី៣ដូចគ្នាតែត្រូវបានបែងចែកនៅក្នុងជំពូកផ្សេងគ្នាដោយសារតែរូបភាពនៃបទល្មើសវាមានលក្ខណៈខុសគ្នា។

**បទល្មើសឆបោក**គឺ មានចែងនៅក្នុងមាត្រាជំពូកទី២ នៃគន្ថីទី៣និយាយអំពីបទល្មើសឆបោក និងបទល្មើសប្រហាក់ប្រហែល។

**បទរំលោភលើទំនុកចិត្ត**គឺ មានចែងនៅក្នុងជំពូកទី៣ នៃគន្ថីទី៣ដូចគ្នាតែនៅក្នុងជំពូកនិយាយអំពីបទល្មើសរំលោភលើទំនុកចិត្ត និងបទល្មើសប្រហាក់ប្រហែល។

**កថាខណ្ឌទី២.ធាតុសត្យានុម័តនៃបទល្មើសទាំងពីរ**

**១.រូបភាពនៃអំពើ**

រាល់ការប្រព្រឹត្តបទល្មើសនីមួយៗតែងតែបង្ហាញមកខាងក្រៅនូវសកម្មភាពល្មើស ហើយសកម្មភាពនោះត្រូវបានកំណត់ថាជាបទល្មើសដោយអំពើរបស់ជនបង្កប្រព្រឹត្តបំពាបំពានទៅលើជនរងគ្រោះ។ ចំណែកឯរូបភាពខុសគ្នារវាងបទល្មើសទាំងពីរខ្ញុំនឹងធ្វើការបកស្រាយនៅក្រោមនេះ៖

➢ **បទល្មើសឆបោក**

- ជនល្មើសបានប្រើល្បិចកលដោយទុច្ចរិតទៅជនរងគ្រោះ។
- ជនរងគ្រោះបានយល់ព្រមប្រគល់នូវទ្រព្យសម្បត្តិផ្សេងៗឱ្យជនល្មើសដោយសារតែជឿលើកលល្បិចរបស់ជនល្មើស។

**ឧទាហរណ៍៖** បុរស ក បានក្លែងថាខ្លួនជាប្រធានក្រុមហ៊ុនមួយដែលអាចរត់ការឱ្យពលករអាចទៅធ្វើការនៅប្រទេសថៃបាន។ ឮដូច្នេះឈ្មោះ ខ ដែលមានបំណងចង់ទៅ

ធ្វើការនៅប្រទេសថៃផងក៏បានប្រគល់ប្រាក់ចំនួន៥០០ដុល្លារ ឱ្យទៅឈ្មោះ ក ដើម្បីបំពេញការងារនេះ។

- **បទល្មើសរំលោភលើទំនុកចិត្ត**
  - ជនរងគ្រោះ និងជនល្មើសបានព្រមព្រៀងគ្នាឈានទៅដល់ការប្រគល់នូវទ្រព្យសម្បត្តិណាមួយឱ្យទៅជនល្មើស។
  - ជនល្មើសមានកាតព្វកិច្ចប្រគល់សងវិញ បង្ហាញ ឬយកមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិនោះ ទៅធ្វើការប្រើប្រាស់ជាកំណត់។
  - ជនល្មើសបានបំពានកាតព្វកិច្ចដោយចេតនា។

**ឧទាហរណ៍៖** លោក ក បានសុំខ្ចីម៉ូតូរបស់លោក ខ ដោយសន្យាថាប្រគល់សងលោក ខ វិញនៅរយៈពេល១០ថ្ងៃក្រោយ។ លោក ខ ក៏បានព្រមព្រៀងប្រគល់ម៉ូតូទៅឱ្យលោក ក ខ្ចីតាមការអះអាង។ រយៈពេល១០ថ្ងៃក្រោយដល់ថ្ងៃកំណត់សងស្រាប់តែលោក ក មិនបានយកម៉ូតូនោះមកប្រគល់សងលោក ខ វិញទេ ព្រោះខ្លួន ក បានយកម៉ូតូនោះទៅលក់យកប្រាក់ចាយអស់ហើយ។

### ២.កម្មវត្ថុនៃបទល្មើស

បទល្មើសនីមួយៗក្រមបានកំណត់យ៉ាងច្បាស់ពីកម្មវត្ថុ នៃបទល្មើស ជាក់ស្តែងបទល្មើសទាំងពីរក្រមព្រហ្មទណ្ឌក៏បានចែងកំណត់ពីកម្មវត្ថុយ៉ាងច្បាស់លាស់ផងដែរ។ កម្មវត្ថុនៃបទល្មើសទាំងពីរនេះទាក់ទងទៅនឹងទ្រព្យសម្បត្តិដូចគ្នាតែវាខុសគ្នាត្រង់ថាបទល្មើសមួយមានកម្មវត្ថុតិច ហើយនិងបទល្មើសមួយទៀតមានកម្មវត្ថុច្រើនជាងតែប៉ុណ្ណោះ។

**បទល្មើសឆបោក** គឺមានកម្មវត្ថុជាច្រើនរួមមាន ការប្រគល់មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ការផ្តត់ផ្គង់សេវា ការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចពីកាតព្វកិច្ច។

**បទល្មើសរំលោភលើទំនុកចិត្ត** គឺមាកម្មវត្ថុដូចជា មូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយតែប៉ុណ្ណោះ។

### ៣.រូបភាពនៃចេតនាប្រព្រឹត្ត

**បទល្មើសឆបោកគឺ** ជាបទល្មើសមួយដែលជនល្មើសមានចេតនាប្រព្រឹត្តតាំងពីមុនសកម្មភាពជនរងគ្រោះការព្រមព្រៀងប្រគល់នូវមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ការផ្គត់ផ្គង់ សេវា និងការធ្វើលិខិតមានតម្លៃជាកាតព្វកិច្ច ឬឱ្យរួចពីកាតព្វកិច្ចទៅឱ្យជនល្មើសម្លេះ។ ជនល្មើសបានរៀបចំគម្រោងទុកជាមុនដោយឧបាយកលទុច្ចរិតយ៉ាងច្បាស់លាស់មុនប្រព្រឹត្តសកម្មភាពល្មើស។

**បទល្មើសរំលោភលើទំនុកចិត្តគឺ** ជាបទល្មើសមួយដែលជនល្មើសមានចេតនាប្រព្រឹត្តល្មើសក្រោយការព្រមព្រៀង នៃការប្រគល់នូវមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយពីជនរងគ្រោះទៅ ឱ្យជនល្មើស។ មានន័យជនល្មើសពីដំបូងគឺ គ្មានចេតនាប្រព្រឹត្តល្មើសទេដោយខ្លួនសន្យាថានឹងប្រគល់សង ឬប្រើតាមការកំណត់នូវមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិទាំងនោះតែក្រោយពីការទទួលនោះជនល្មើសក៏បានបំពាននូវកាតព្វកិច្ចប្រគល់សង ឬប្រើប្រាស់ខុសពីគោលដៅដែលជនរងគ្រោះជនបាន។

# សេចក្តីសន្និដ្ឋាន

ផ្អែកតាមការសិក្សាស្រាវជ្រាវ និងការបកស្រាយកន្លងមករវាងបទល្មើសឆបោក និងរំលោភលើទំនុកចិត្ត នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាយើងបច្ចុប្បន្ននេះ បានឆ្លុះបញ្ចាំង ឱ្យឃើញអំពីប្រភពនីត្យានុកូលភាព (នីត្យានុកូលនៃបទល្មើស និងនីត្យានុកូលភាពនៃទោស) នៃប្រព័ន្ធច្បាប់ខ្មែរ ដែលបានកំណត់ចែងយ៉ាងច្បាស់លាស់ និងត្រឹមត្រូវដែលមិនអាចប្រកែកបាន ដោយចាប់បង្ខំឱ្យមនុស្សគ្រប់ៗរូប ដែលរស់នៅក្នុងសង្គមត្រូវតែគោរព ហើយនិងជៀសវាងឱ្យបាននូវការប្រព្រឹត្តអំពើទាំងឡាយណាដែលបង្កផលប៉ះពាល់នាំឱ្យកើតមានព្យសនកម្ម ដល់សណ្តាប់ធ្នាប់សង្គម និងសិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ៗ។ មួយវិញទៀតការផ្សព្វផ្សាយច្បាប់ឱ្យប្រជាពលរដ្ឋមានការយល់ដឹងកាន់តែច្រើនដោយអនុវត្តតាមប្រព័ន្ធផ្សព្វផ្សាយចម្រុះមានការកើនឡើងដើម្បីកាត់បន្ថយការប្រព្រឹត្តបទល្មើស។ ចំពោះការអនុវត្តដំណើរការនីតិវិធី នៅក្នុងប្រព័ន្ធតុលាការ បានផ្តល់នូវជំនឿទុកចិត្ត និងភាពយុត្តិធម៌ដល់ប្រជាពលរដ្ឋ បើទោះបីជាមានចំណុចខ្វះខាតមួយចំនួនក៏ពិតមែន។

ឆ្លើយតបតាមការសិក្សាកន្លងមកនេះយើងខ្ញុំ បានលើកយកបទល្មើសចំនួនពីរមាត្រាមកធ្វើការប្រៀបធៀបគឺ មាត្រា៣៧៧ បទល្មើសឆបោក និងមាត្រា៣៩១ បទល្មើសរំលោភលើទំនុកចិត្ត។ យើងបានរៀបរាប់អំពីសញ្ញាណនៃបទល្មើសទាំងពីររួចរាល់មកហើយ អ្វីដែលយើងគួរកត់សម្គាល់ខ្លាំងជាងគេគឺ លក្ខណៈដូចគ្នា និង លក្ខណៈខុសគ្នា នៃបទល្មើសទាំងពីរ។ លក្ខណៈដូចមានដូចជា៖ ធាតុនីត្យានុកូល (ក្រមព្រហ្មទណ្ឌចែងកំណត់ថាជាបទល្មើស ហើយត្រូវផ្តន្ទាទោស) ចែងក្នុងគន្ថីទី៣ (បទល្មើសប្រឆាំង និងទ្រព្យសម្បត្តិ) មាតិកាទី១ (ការយកទ្រព្យសម្បត្តិអ្នកដ៏ទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយទុច្ចរិត) ចំណាត់ថ្នាក់នៃបទល្មើស (បទមជ្ឈិមផ្តន្ទាទោសពន្ធនាគារពី ៦ថ្ងៃ ដល់ក្រោម ឬ ស្មើនឹង ៥ឆ្នាំ) អាជ្ញាយុកាលនៃទោស និងបទល្មើស (រយៈពេល ៥ឆ្នាំ) ការប៉ុនប៉ង (បទល្មើសទាំងពីរក្រមបានកំណត់ពីការប៉ុនប៉ងមានទោសដូចគ្នា) ធាតុអត្តនោម័ត (ជនល្មើសគឺ បានប្រព្រឹត្តអំពើល្មើសដោយចេតនា ដោយខ្លួនបានប្រើល្បិចធ្វើឱ្យជនរងគ្រោះប្រគល់នូវទ្រព្យសម្បត្តិ

ឬវត្ថុមានតម្លៃផ្សេងៗមកឱ្យខ្លួន)។ រីឯចំណុចខុសគ្នាមានដូចជាៈ ធាតុនីត្យានុកូល (និយមន័យបទល្មើសទាំងពីរ) ចែងក្នុងមាត្រា (មាត្រា៣៧៧ បទឆបោក និងមាត្រា៣៩១ បទរំលោភលើទំនុកចិត្ត) ចែងក្នុងជំពូក (បទឆបោក ជំពូកទី២ រីឯ បទរំលោភលើទំនុកចិត្ត ជំពូកទី៣) ចេតនានៃការប្រព្រឹត្តបទល្មើសទាំងពីរមួយកើតមុនការប្រគល់កម្មវត្ថុ មួយទៀត ចេតនាប្រព្រឹត្តកើតក្រោយការប្រគល់កម្មវត្ថុនៃបទល្មើស។ ស្ថានទម្ងន់ទោស (បទឆបោកមានពីមាត្រា៣៧៩ និង មាត្រា៣៨០ រីឯបទរំលោភលើទំនុកចិត្តមានតែមួយមាត្រា៣៩៦) ទោសបន្ថែម (បទឆបោកមាន ១៣ចំណុច រីឯ បទរំលោភលើទំនុកចិត្តមាន ១០ចំណុច) ជាដើម៕

# អនុសាសន៍

ឆ្លងកាត់តាមការបកស្រាយ និងចុះស្រាវជ្រាវឯកសារលើប្រធានបទស្តីការប្រៀបធៀបទល្មើសឆបោក និងរំលោភលើទំនុកចិត្តកន្លងមកយើងឃើញថាស្ថាប័នអនុវត្តច្បាប់ និងបទល្មើសទាំងពីរនេះគឺនៅមានចំណុចខ្វះចន្លោះមួយចំនួនគួរត្រូវបានកែតម្រូវ និងបំពេញបន្ថែមដើម្បីងាយស្រួលក្នុងការអនុវត្ត និងសិក្សាស្វែងយល់របស់សិស្ស និស្សិតរួមមាន៖

## ចំណុចខ្សោយ

- ការផ្សព្វផ្សាយច្បាប់គឺ ពុំសូវបានទូលំលាយដល់សាធារណៈជនទូទៅដូច្នេះធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនបានប្រព្រឹត្តបទល្មើសមានការកើនឡើង
- ស្ថាប័នអនុវត្តច្បាប់សព្វថ្ងៃគឺ មិនមានគោលការណ៍រួមណាមួយសម្រាប់បទល្មើសទាំងពីរយកមកអនុវត្តដូចគ្នាទេ
- ការចែករំលែកនូវចំណេះដឹង ឬឯកសាររបស់ស្ថានប័នអនុវត្តច្បាប់គឺ នៅមានកម្រិត
- តុលាការមិនមានយុត្តិសាស្ត្រសម្រាប់អនុវត្តដូចប្រទេសមួយចំនួននៅលោកខាងលិច ដូចជាប្រទេសអង់គ្លេស បារាំង អាល្លឺម៉ង់...។
- ក្រមមិនបានកំណត់ការបំពានកិច្ចសន្យាប្រភេទណាមួយជាបទល្មើសរំលោភលើទំនុកចិត្តឡើយ ដូចច្នេះធ្វើឱ្យអ្នកអនុវត្តពិបាកនឹងចោទប្រកាន់នៃបទល្មើសនេះ ហើយអាចធ្វើឱ្យមានការភាន់ច្រឡំរវាងបទល្មើសរំលោភលើកទំនុកចិត្ត និងការបំពានកាតព្វកិច្ច។
- រាល់បទល្មើសនីមួយៗក្រសួង ឬ អង្គការនីតិបញ្ញត្តិគួរតែពន្យល់ឱ្យបានច្បាស់លាស់ដើម្បីងាយស្រួលក្នុងការអនុវត្ត កុំឱ្យផ្ទុយពីគោលបំណង ឬខ្លឹមសារនៃបទល្មើសនីមួយៗ ។

## ចំណុចខ្លាំង

- បទល្មើសទាំងបានចែងយ៉ាងច្បាស់លាស់នៅក្នុងក្រមព្រហ្មទណ្ឌ
- បានបង្កើតសាលាដំបូងតុលាការគ្រប់រាជធានី ខេត្តដើម្បីបង្កលក្ខណៈងាយស្រួលសម្រាប់ប្រជាពលរដ្ឋក្នុងការដាក់ពាក្យបណ្តឹង លើកលែងតែខេត្តកែបមួយដែលស្ថិតនៅក្រោមសមត្ថកិច្ចតុលាការខេត្តកំពត
- ស្ថាប័នអនុវត្តច្បាប់បង្កើតឱ្យមានតុលាការជំនាញទៅតាមប្រភេទរឿងក្តី
- បទល្មើសរំលោភលើសេចក្តីទុកចិត្តមាត្រា៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលមានសេចក្តីណែនាំរួមរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូលវាមានអត្ថន័យដូចគ្នានឹងមាត្រា៣៩១នៃក្រមព្រហ្មទណ្ឌសព្វថ្ងៃនេះដែរ។
- មានស្ថាប័នជំនាញកំពុងបណ្តុះបណ្តាលថៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី គឺរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

## ដំណោះស្រាយ

- អប់រំ និងផ្សព្វផ្សាយច្បាប់ឱ្យបានទូលំលាយទោះជានៅតំបន់ដាច់ស្រដាលក៏ដោយ
- ស្ថាបប័ននីមួយៗត្រូវតែមានការយកចិត្តទុកដាក់ចែករំលែកចំណេះដឹង ឬឯកសារផ្សេងៗដល់សិស្ស និស្សិតដើម្បីឱ្យពួកគេបានស្វែងយល់ពីការងារ និងដំណើរការប្រព្រឹត្តទៅរបស់ស្ថាប័នខ្លួន។
- ក្រសួងយុត្តិធម៌ ស្ថាប័នតុលាការ ឬអង្គភាពដែលពាក់ព័ន្ធគួរតែមានសេចក្តីណែនាំឬយុត្តិសាស្ត្រសម្រាប់ពន្យល់ពីបទល្មើសណាមួយដើម្បីកុំឱ្យមានការភាន់ច្រឡំគ្នា

# ឯកសារយោង

## ១.ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១០
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
- ច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល
- សេចក្តីណែនាំរួមលេខ០២ រវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូល ស្តីពីមាត្រា៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល(រំលោភលើសេចក្តីទុកចិត្ត) ២០០៥

## ២.សៀវភៅដែលពាក់ព័ន្ធ និងឯកសារផ្សេងៗ

- សៀវភៅនីតិព្រហ្មទណ្ឌទូទៅរបស់សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធឆ្នាំ២០០៩
- សៀវភៅទោសព្រហ្មទណ្ឌ សាស្ត្រា កៅ សីហា ឆ្នាំ២០១៣
- សៀវភៅស្តីពីការពិភាក្សាលើវិស័យឯកជន លេខ២៣ រឿងក្តីអំពីការរំលោភលើទំនុកចិត្ត
- សៀវភៅនីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យកៅ សីហា ឆ្នាំ២០១៤
- មេរៀនក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដោយ លោក សឿន មុនីរ័ត្ន (ព្រះរាជអាជ្ញាខេត្តកំពង់ឆ្នាំង) ឆ្នាំ២០១១
- សហប្រតិបត្តិការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ នីតិព្រហ្មទណ្ឌ
- ឯកសារសិក្ខាសាលាស្តីពី នីតិព្រហ្មទណ្ឌ និង នីតិគ្រួសារនៅបញ្ជាការដ្ឋានកងពលតូចលេខ៧០ ដោយសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត

# ឧបសម្ព័ន្ធ

# តារាងឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១. បទល្មើសឆបោក

១.ក្រមព្រហ្មទណ្ឌ

២.ពាក្យបណ្តឹង

៣.ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

៤.របាយការសំយោគ

៥.ដីកាសន្និដ្ឋានស្ថាពរ

ឧបសម្ព័ន្ធ២. បទល្មើសរំលោភលើទំនុកចិត្ត

១.ក្រមព្រហ្មទណ្ឌ

២.សេចក្តីណែនាំរួមលេខ០២ រវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូលស្តីពីការអនុវត្តមាត្រា៤៦ បទរំលោភលើសេចក្តីទុកចិត្តនៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៣.ពាក្យបណ្តឹង

៤.ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

៥.របាយការសំយោគ

៦. ដីកាសន្និដ្ឋានស្ថាពរ

៧.សាលក្រម